**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍតំបន់ច្រោយចទ្វារ
# ( អូស៊ីអាយស៊ី២០១៧-២០២៥ )

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. រី ស៊ីមួយ**

**អ៊ុក វិច្ឆិកា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍតំបន់ច្រោយចង្វារ

# (អូស៊ីអាយស៊ី២០១៧-២០២៥)

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. រី ស៊ីមួយ**

**អ៊ុក វិច្ឆិកា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

## **សេចក្ដីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **រី ស៊ីមួយ** និងខ្ញុំបាទឈ្មោះ **អ៊ុក ទិច្ឆិកា**ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០២២-២០២៣។

ជាបឋមនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់មានកិត្តិយសសូមសេចក្ដីអនុញ្ញាតដើម្បីបានសម្ដែងនូវភារកិច្ចគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេ គឺ**លោកឪពុក និងអ្នកម្ដាយ** ដែលបានខិតខំប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ថែរក្សាលះបង់ទាំងកម្លាំងកាយទាំងកម្លាំងចិត្ត លះបង់ទាំងធនធាន សេចក្ដីស្រឡាញ់ ភាពកក់ក្ដៅសព្វបែបសព្វយ៉ាង ព្រមទាំងទឹកចិត្តដ៏បរិសុទ្ធចំពោះកូន និងបានខិតខំជម្រុញឱ្យកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ដើម្បីឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនទៅដល់ **ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំប្រឹងប្រែង និងលទ្ធភាពគ្រប់សព្វបែបសព្វយ៉ាងក្នុងការដឹកនាំក្នុងគោលបំណងបណ្ដុះបណ្ដាលមូលធនផ្នែកបញ្ញាស្មារតី ធនធានមនុស្សនៅក្នុងកម្ពុជាឱ្យមានចំណេះដឹងបទពិសោធន៍ សីលធម៌ ព្រមទាំងគុណធម៌ និងសមត្ថភាពខ្ពស់ដើម្បីក្លាយជាសសរទ្រូងរបស់ប្រទេសកម្ពុជាដែលស្របទៅតាមកាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

ជាពិសេសសូមគោរពថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត អ៊ុន សកក្ខដា** ដែលបានដឹកនាំព្រមទាំងកែលម្អ និងធ្វើចង្អុលបង្ហាញតម្រង់ទិសព្រមទាំងពន្យល់ពីវិធីសាស្ត្រល្អៗផ្ដល់យោបល់ល្អៗទាក់ទង និងប្រធានបទសារណារបស់នាងខ្ញុំ និងខ្ញុំបាទរួមទាំងការចំណាយនូវពេលវេលាដ៏មានតម្លៃតាំងពីដើមរហូតដល់ការបញ្ចប់ការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់។

ជាចុងក្រោយនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់មានកត្តិយសសូមនូវសេចក្ដីអនុញ្ញាតគោរពជូនទៅដល់អ្នកមានគុណទាំងទ្វេ សូមមេត្តាទទួលយកដោយក្ដីអនុគ្រោះបំផុត នូវភក្ដីភាព សេចក្ដីស្រឡាញ់ គោរពស្រឡាញ់ក្នុងភាពសុចរិតដែលប្រកបទៅដោយ គុណតម្លៃដ៏ឧត្តុងឧត្តមនៃសេចក្ដីថ្លៃថ្នូរ ភាពចុំច្រើន កត្តិគុណដ៏ខ្ពង់ខ្ពស់បំផុតព្រមទាំងកត្តញ្ញូតាធម៌បំផុតអំពីនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់។ សូមគោរពជូនពរឱ្យលោកអ្នកមានគុណទាំងទ្វេ សូមឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃ អាយុយឺនយូរ ឱ្យរកទទួលទានមានបានគ្រប់ៗគ្នាព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់បានសិក្សាថ្នាក់បរិញ្ញាបត្រ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកនីតិសាស្ត្រ អស់រយៈពេល ០៣ឆ្នាំកន្លងទៅនេះនាងខ្ញុំ និងខ្ញុំបាទទទួលបាននូវចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី ព្រមទាំងការអនុវត្តនៅក្នុងនោះផងដែរ។ ក្នុងដំណាក់កាលនេះ ជាឆ្នាំទី៤របស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់ដោយផ្អែកទៅតាមលទ្ធភាពចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយជាកត្តាយ៉ាងសំខាន់ដែលអាចជំរុញឱ្យនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់មានឱកាសក៏ដូចជាលទ្ធភាពដែលអាចសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ គឺជាស្នាដៃដែលអាចវាស់ស្ទង់នូវសមត្ថភាព និងចំណេះដឹងរបស់នាងខ្ញុំ និងខ្ញុំបាទដែលមានតាំងពីមុនមក។ បរិបទបែបនេះហើយជាហេតុបណ្តាលឱ្យនាងខ្ញុំ និងខ្ញុំបាទបានពិភាក្សាគ្នាសម្រេចជាឯកច្ឆន្ទដើម្បីធ្វើការជ្រើសរើសប្រធានបទដែលទាក់ទងទៅ និងនីតិនគរូបនីយកម្ម និងសំណង់ដែលស្តីអំពី **ការអភិវឌ្ឍតំបន់ជ្រោយចង្វារ** ( **អូស៊ីអាយស៊ី២០១៧-២០២៥** ) មកធ្វើជាប្រធានបទនៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។ កម្មវត្ថុសំខាន់មួយទៀត គឺនាងខ្ញុំ និងខ្ញុំបាទចង់ឱ្យនិស្សិតជំនាន់ក្រោយៗ សាធារណៈជនបានសិក្សា និងស្វែងយល់បន្ថែមអំពីផែនការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥) ព្រមទាំងបានបង្ហាញពីសោភ័ណភាពតំបន់ប្រណីតភាពនៃសំណង់ ការរស់នៅហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធបច្ចេកទេសទំនើបនៃការរៀបចំតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥) ផងដែរ។ លើសពីនេះទៅទៀតចំពោះសារណាបញ្ចប់ការសិក្សាមួយនេះនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់ក៏មានគោលបំណងចង់បង្ហាញពីសក្តានុពលភាពនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥) មួយនេះផងដែរ។

មុននឹងបញ្ចប់នាងខ្ញុំ និងខ្ញុំបាទសូមគោរព និងទទួលយកនូវកំហុសខុសឆ្គងដែលកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី ឬនៅមានភាពខ្វះចន្លោះនៅត្រង់កន្លែងណាមួយ សូមមេត្តាខន្តី អភ័យទោសប្រកបដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់ជាមួយគ្នានេះផងនាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់សូមស្វាគមន៍នូវរាល់មតិ រិះគន់ កែលម្អ នូវរាល់ចំណុចខ្វះខាតទាំងឡាយក្នុងអត្ថន័យស្ថាបនា ដើម្បីឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់មានអត្ថន័យគ្រប់គ្រាន់ និងកាន់តែមានភាពល្អប្រសើរឡើង។

ជាទីបញ្ចប់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់សូមគោរពជូនពរឱ្យអ្នកអាន មិត្តនិស្សិតទាំងអស់គ្នា ឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃ មានអាយុយឺនយូរ និងរកទទួលទានមានបានគ្រប់ៗគ្នាហើយព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម**........................................................................................... ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអេយស៊ី២០១៧-២០២៥)

**១.១. ស្ថានភាពទូទៅនៃតំបន់ជ្រោយចង្វារ**.................................................... ៤
១.១.១. ទីតាំងភូមិសាស្ត្រនៃតំបន់ជ្រោយចង្វារ........................................................ ៥
១.១.២. ស្ថានភាពប្រជាសាស្ត្រ.............................................................................. ៥
**១.២. មូលហេតុដែលនាំឱ្យមានការរៀបចំតំបន់ជ្រោយចង្វារ**.................................... ៦
១.២.១. កំណើនប្រជាជន..................................................................................... ៦
១.២.២. ភាពក្រីក្រ............................................................................................. ៧
១.២.៣. តម្រូវការចាំបាច់នៃការរស់នៅ.................................................................... ៧
១.២.៤. ការដាក់សម្ពាធបរិស្ថាន........................................................................... ៨
**១.៣. ការអភិវឌ្ឍតាមវិស័យ**................................................................................ ៨
១.៣.១. វិស័យសេដ្ឋកិច្ចនិងវិស័យសង្គមកិច្ច........................................................... ៨
១.៣.២. វិស័យទេសចរណ៍................................................................................. ១០
១.៣.៣. វិស័យគមនាគមន៍................................................................................ ១១
១.៣.៤. វិស័យដែលពាក់ព័ន្ធ.............................................................................. ១៣
**១.៤. ការថែរក្សាបរិស្ថានចំពោះការបំពុលទាំង៥**.................................................. ១៤
១.៤.១. ការបំពុលទឹក....................................................................................... ១៤
១.៤.២. ការបំពុលខ្យល់..................................................................................... ១៥
១.៤.៣. ការបំពុលសំឡេង.................................................................................. ១៧
១.៤.៤. ការបំពុលដោយសំណល់រឹងរាវ.................................................................. ១៨
១.៤.៥. ការបំពុលដី......................................................................................... ២០

## ជំពូកទី២

## ការអភិវឌ្ឍតំបន់ច្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥)

**២.១. សញ្ញាណទូទៅនៃតំបន់ អូស៊ីអាយស៊ី** ............................................................ ២៣
២.១.១. អំពីក្រុមហ៊ុន អូស៊ីអាយស៊ី ............................................................ ២៣
២.១.២. សកម្មភាពរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី ............................................................ ២៥
**២.២. ការរៀបចំតំបន់ អូស៊ីអាយស៊ី នៃខណ្ឌច្រោយចង្វារប្រកបទៅដោយស្តង់ដារ**.. ២៥
២.២.១. តំបន់ដែលមានសណ្តាប់ធ្នាប់ ............................................................ ២៦
២.២.២. សន្តិសុខ ............................................................ ២៦
២.២.៣. ភាពស្ងប់ស្ងៀម ............................................................ ២៩
២.២.៤. ការថែរក្សាបរិស្ថាន ............................................................ ៣០
២.២.៥. ប្លង់គោល ............................................................ ៣១
**២.៣. ការរៀបចំសោភ័ណភាពនៃតំបន់ច្រោយចង្វារ អូស៊ីអាយស៊ី** ............................................................ ៣២
២.៣.១. សោភ័ណភាពពេលថ្ងៃ ............................................................ ៣២
២.៣.២. សោភ័ណភាពពេលយប់ ............................................................ ៣២
**២.៤. គម្រោងដែលកំពុងអភិវឌ្ឍន៍ក្នុងតំបន់ច្រោយចង្វារ អូស៊ីអាយស៊ី** ............................................................ ៣៣
២.៤.១. គម្រោងដែលសម្រេចបាន ............................................................ ៣៣
២.៤.២. គម្រោងកំពុងអភិវឌ្ឍន៍ ............................................................ ៣៤
២.៤.៣. គម្រោងកំពុងស្ថិតក្នុងកាសិក្សា ............................................................ ៣៥
**សេចក្តីសន្និដ្ឋាន** ............................................................ ៣៦
**អនុសាសន៍** ............................................................ ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានព្រំប្រទល់ជាប់ និងប្រទេសថៃ ឡាវ វៀតណាម និងមីយ៉ានម៉ា ជាមួយគ្នានេះផងដែរប្រទេសកម្ពុជាក៏ធ្លាប់ឆ្លងកាត់នូវសង្គ្រាមជាច្រើនឆ្នាំដែលនាំឱ្យមានការខូចខាតយ៉ាងច្រើននូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ជាពិសេសបាត់បង់នូវធនធានមនុស្សជាច្រើនផងដែរ។ យ៉ាងណាមិញបន្ទាប់ពីប្រទេសកម្ពុជាទទួលបានមកនូវសុខសន្តិភាពនូវក្រោមគោលនយោបាយឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយើងសង្កេតឃើញថា ប្រទេសកម្ពុជា និងកំពុងតែមានការអភិវឌ្ឍរីកចម្រើនលូតលាស់លើគ្រប់វិស័យមិនថារដ្ឋ ឬឯកជន។ កាន់តែពិសេសជាងនេះទៅទៀតនោះ យើងឃើញថាវិស័យផ្សេងៗ ជាច្រើនត្រូវបានរីកចម្រើនគួបផ្សំជាមួយ និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាប្រព័ន្ធគមនាគមន៍ សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ វត្តអារាម គ្រឹះស្ថានស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជន ហើយព្រមទាំងមាននូវសំណង់អាគារតូចធំ លំនៅឋានផ្សេងៗជាច្រើនទៀតបានរីករាលដាលជាបន្តបន្ទាប់ទន្ទឹមជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺបានគិតគូរយ៉ាងយកចិត្តទុកដាក់ខ្លាំងបំផុតសម្រាប់ការរស់នៅជាពិសេសនោះ គឺការអភិវឌ្ឍនៅតំបន់ផ្សេងៗ មិនថាទីក្រុង ឬទីជនបទក្នុងគោលបំណងដើម្បីបំពេញបាននូវតម្រូវការរស់នៅរបស់ប្រជាជនឱ្យកាន់តែមានភាពល្អប្រសើរឡើងជាមួយ និងទំនើបកម្មនៃការរស់នៅ និងសោភ័ណភាពនៃទីក្រុង។

ខណៈពេលដែលប្រទេសកម្ពុជា ស្ថិតក្នុងដំណាក់កាលដែលជាប្រទេសដែលកំពុងតែមានការអភិវឌ្ឍខ្លាំង រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា គឺបានខិតខំយកចិត្តទុកដាក់អភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់។ ក្នុងនោះផងដែរ ដើម្បីបង្កជាលក្ខណៈងាយស្រួលនៅក្នុងការអភិវឌ្ឍរាជរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការរៀបចំអភិវឌ្ឍន៍លើគ្រប់វិស័យព្រមទាំងរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពបរិស្ថានដែលកត្តាទាំងពីរនេះ គឺផ្តោតសំខាន់ទៅលើបរិស្ថានទីក្រុងដែលគ្មានការបំពុលផ្សេងៗ សម្រាប់ការរស់នៅរបស់ប្រជាជនហើយបូករួមផ្សំទាំងមានសណ្តាប់ធ្នាប់ល្អ មានសន្តិសុខ និងមានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង និងនៅក្នុងតំបន់ជាពិសេស គឺទទួលបាននូវទំនើបកម្មនៃការរស់នៅសម្រាប់ប្រជាជនក្នុងតំបន់ជ្រោយចង្វារនេះតែម្តង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យទទួលបាននៅលក្ខណៈស៊ីជម្រៅ ក៏ដូចជាភាពកាន់តែច្បាស់លាស់បន្ថែមទៀតនោះលើប្រធានបទសារណាខាងលើនាងខ្ញុំ និងខ្ញុំបាទទាំងពីរបានលើកនូវចំណោទបញ្ហាដើម្បីធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន តើមានកត្តាអ្វីខ្លះដែលអាចបណ្តាលឱ្យមានការអភិវឌ្ឍតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី និងមានកត្តារួមផ្សំអ្វីខ្លះ? ម្យ៉ាងវិញទៀត តើគួរធ្វើដូចម្តេចខ្លះដើម្បីឱ្យការរៀបចំតំបន់ជ្រោយចង្វារមួយនេះទទួលបានលក្ខណៈ

ល្អប្រសើរក៏ដូចជាមានភាពរីកចម្រើននៃការអភិវឌ្ឍតំបន់នោះតាមស្តង់ដារអូស៊ីអាយស៊ី?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទដែលទាក់ទង និងនីតិនគរូបនីយកម្មស្តីអំពី **ការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥)** យកមកសរសេរជាប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ គឺមានគោលបំណងចង់បង្ហាញអំពីសក្តានុពលនៃការអភិវឌ្ឍរបស់ខណ្ឌជ្រោយចង្វារពីព្រោះពេលបច្ចុប្បន្ននេះយើងឃើញថាតំបន់ អូស៊ីអាយស៊ី គឺបាន និងកំពុងតែទាក់ទាញនូវការវិនិយោគជាច្រើនក្នុងនោះផងដែរមិនថាហេដ្ឋារចនាសម្ព័ន្ធ សំណង់អាគារទំនើបៗ លំនៅឋានប្រណីតៗ ផ្សារ សាលារៀន មន្ទីរពេទ្យក៏ដូចជាកន្លែងកំសាន្តផ្សេងៗ សុទ្ធតែមានលក្ខណៈស្តង់ដារជាតិ និងអន្តរជាតិដែលអាចបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះកាន់តែមានភាពប្រសើរឡើង។

បន្ថែមពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានបទសារណាមួយនេះ គឺមានគោលបំណងក្នុងការបង្ហាញអំពីការអភិវឌ្ឍប្រកបទៅដោយសក្តានុពលនៃការរៀបចំនៅក្នុងតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី ឱ្យប្រែក្លាយទៅជាតំបន់ដែលមានសណ្តាប់ធ្នាប់ល្អជាមួយ និងសោភ័ណភាពនៅក្នុងទីក្រុងជាមួយ និងគុណភាពនៃការរស់នៅរបស់ប្រជាជនដែលនៅក្នុងតំបន់ជ្រោយចង្វារជាមួយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ជាការពិតណាស់រាល់ស្នាដៃសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធតែមាននូវគោលបំណងសំខាន់ៗនៅក្នុងកិច្ចការស្រាវជ្រាវនោះ។ យ៉ាងណាមិញការសិក្សាស្រាវជ្រាវដែលទាក់ទង និងការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដារ អូស៊ីអាយស៊ី គឺនាងខ្ញុំ និងខ្ញុំបាទចង់បកស្រាយ និងធ្វើការបង្ហាញនូវលក្ខណៈការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដារ អូស៊ីអាយស៊ី តាមរយៈការរៀបចំទៅតាមដំណាក់កាលនីមួយៗដែលស្របទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាលក៏ដូចជាស្តង់ដារ និងប្រណីតភាពនៃការរស់នៅ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើអត្ថបទសារណាមួយនេះ គឺមានគោលបំណងសំខាន់ដើម្បីផ្តល់ជាសារៈប្រយោជន៍ដល់មិត្តនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅអំពីផែនការសកម្មភាពនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារទៅតាមស្តង់ដារ អូស៊ីអាយស៊ីជាមួយ និងការអភិវឌ្ឍលើវិស័យផ្សេងៗមិនថាហេដ្ឋារចនាសម្ព័ន្ធការវិនិយោគ បច្ចេកទេសនៃការសាងសង់ និងការរៀបចំសំណង់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធ ទាំងអស់ដែលអាចអភិវឌ្ឍន៍តាមស្តង់ដារ អូស៊ីអាយស៊ី។

មិនត្រឹមតែប៉ុណ្ណោះ អត្ថបទសារណាមួយនេះក៏បានចូលរួមចំណែកនៅក្នុងការបង្ហាញនៃការជំរុញឱ្យមានការអភិវឌ្ឍថ្មីៗបន្ថែមទៀតផងដែរ។

## ៦. វិធីសាស្រ្តនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទសារណាមួយនេះគឺនាងខ្ញុំ និងខ្ញុំបាទបានស្វែងរកបណ្តាឯកសារដែលពាក់ព័ន្ធ និងប្រធានបទសារណានៅក្នុងបណ្ណាល័យនីតិសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សាលាខណ្ឌជ្រោយចង្វារ តាមប្រព័ន្ធអ៊ីនធឺណិត និងគេហទំព័រផ្សេងៗដោយក្នុងនោះនាងខ្ញុំ និងខ្ញុំបាទបានប្រមូលឯកសារយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ និងខ្ញុំបាទទាំងពីរនាក់ត្រូវបានបែងចែកជាពីរជំពូកគឺ៖

- **ជំពូកទី១ សញ្ញាណទូទៅនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារ** (**អូស៊ីអាយស៊ី២០១៧-២០២៥**) នៅក្នុងជំពូកនេះនាងខ្ញុំ និងបែងចែកជាចំណុចធំៗបន្ថែមទៀត ដោយចំណុចទី១និយាយអំពីស្ថានភាពទូទៅនៃតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥) ចំណុចទី២ដែលនិយាយអំពីបុព្វហេតុដែលនាំឱ្យមានការរៀបចំតំបន់ជ្រោយចង្វារ ចំណុចទី៣និយាយអំពីការអភិវឌ្ឍតាមវិស័យ និងចំណុចទី៤និយាយអំពីការថែរក្សាបរិស្ថានចំពោះការបំពុលទាំង៥។
- **ជំពូកទី២ ការអភិវឌ្ឍតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី** (**២០១៧-២០២៥**) ជំពូកនេះខ្ញុំបាទ និងធ្វើការបែងចែកជាចំណុចធំៗបន្ថែមទៀតដោយ ចំណុចទី១និយាយអំពីសញ្ញាណទូទៅនៃតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី ចំណុចទី២ការរៀបចំតំបន់អូស៊ីអាយស៊ីនៃខណ្ឌជ្រោយចង្វារប្រកបទៅដោយស្តង់ដារ ចំណុចទី៣និយាយអំពីការរៀបចំសោភ័ណភាពនៃតំបន់ជ្រោយចង្វារ និងចំណុចទី៤និយាយអំពីគម្រោងកំពុងអភិវឌ្ឍន៍ក្នុងតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី។

# ជំពូកទី១

# សញ្ញាណទូទៅនៃការអភិវឌ្ឍ
# តំបន់ព្រៃឈើចម្រុះអ៊ីរ៉ែយសុី

# (២០១៧-២០២៥)

# ជំពូកទី១

# សញ្ញាណទូទៅនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអេយស៊ី ២០១៧-២០២៥)

## ១.១. ស្ថានភាពទូទៅនៃតំបន់ជ្រោយចង្វារ

នៅក្នុងរាជធានីភ្នំពេញមានខណ្ឌចំនួន ១៤ខណ្ឌ និងសង្កាត់ចំនួន ១០៥សង្កាត់។ ក្នុងចំណោមខណ្ឌទាំង ១៤នោះ គឺមានខណ្ឌ ២ទើបតែបង្កើត គឺខណ្ឌបឹងកេងកង និងខណ្ឌកំបូល។ ខណ្ឌថ្មីទាំង ២នេះបានកាត់សង្កាត់មួយចំនួនពីខណ្ឌផ្សេងៗពោល គឺខណ្ឌបឹងកេងកង (ថ្មី)[១] និងខណ្ឌកំបូល (ថ្មី)។[២] ជាមួយគ្នានេះផងដែរបើយើងឈរមើលនៅប៉ែកខាងលិចនៃមាត់ទន្លេយើងតែងតែសម្លឹង និងមើលទៅកាន់តំបន់ត្រើយម្ខាងទៀតនៃដងទន្លេនៅភាគខាងកើតឈាងខាងជើងដែលជាតំបន់ជ្រោយចង្វារដែល និងកំពុងតែលូតលាស់យ៉ាងខ្លាំង និងជាផ្នែកដ៏សំខាន់នៃទីក្រុងភ្នំពេញ។ ហើយខណ្ឌជ្រោយចង្វារលាតសន្ធឹងចាប់ពីចន្លោះដងទន្លេមេគង្គ និងទន្លេសាបទៅដល់តំបន់កោះដាច់ និងកោះឧកញ៉ាតី។

ខណ្ឌជ្រោយចង្វារ គឺមានចំនួន ០៥សង្កាត់រួមមាន ព្រែកលាប ព្រែកតាសេក ជ្រោយចង្វារ បាក់ខែង និងកោះដាច់។ នៅក្នុងតំបន់ជ្រោយចង្វារក៏មានទីតាំងសក្តានុពលធំៗចំនួន ០៩នៅក្នុងទីក្រុងជ្រោយចង្វារដូចជា អាគារពន្ធដារថ្មី មជ្ឈមណ្ឌលសន្និបាទអន្តរជាតិជ្រោយចង្វារ សកលវិទ្យាល័យខេមតិច សាលាជាតិគយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអធ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មន្ទីសាធារណការ និងដឹកជញ្ជូន រួមទាំងសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) និងផ្សារទំនើប ប៊ីកស៊ី ជាដើមដែលនឹងមានវត្តមាននូវពេលឆាប់ៗនេះ។ ម្យ៉ាងទៀតតំបន់ជ្រោយចង្វារមាននូវលក្ខណៈពិសេសជាច្រើនផ្សេងទៀតដូចជា នៅជិតកន្លែងអប់រំល្បីៗជាច្រើន ទាំងជាតិ និងអន្តរជាតិដូចជា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យន័រតុន និងសាលាអន្តរជាតិអូស្ត្រាលីភ្នំពេញជាដើម។ ម្យ៉ាងទៀតរួមមានទាំងបណ្តាញផ្លូវដែលតភ្ជាប់ដោយផ្លូវជាតិលេខ៦អាដែលជាផ្លូវដ៏សំខាន់ភ្ជាប់ទៅតាមបណ្តាខេត្តមួយចំនួនទៀតដែលរួមមាន ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាម។ ពិសេសជាងនេះទៅទៀតតំបន់ជ្រោយចង្វារក៏នៅជិតកន្លែងផ្តល់សេវាវេជ្ជសាស្ត្រធំៗ ដូចជា មន្ទីពេទ្យសាន់រ៉ាយជប៉ុន និងមន្ទីពេទ្យកាល់ម៉ែត្រជាដើម។ លើសពីនេះទៅទៀតតំបន់ជ្រោយចង្វារ គឺព័ទ្ធជុំវិញទៅដោយ ភោគនីយដ្ឋានល្បីៗ ហាងកាហ្វេ ផ្សារទំនើបជាច្រើន ហើយតំបន់ជ្រោយចង្វារក៏នៅជិតតំបន់កំសាន្តជាច្រើនដូចជា សាហ្វារីវើល សួនទឹក ពហុកីឡាដ្ឋានមរកតេជោ កោះដាច់ និងតំបន់ជាច្រើនទៀតហើយនៅក្បែរស្ពានឆ្លងកាត់ទន្លេ គឺស្ពាន មិត្តភាពកម្ពុជា-ជប៉ុន និងស្ពាន មិត្តភាពកម្ពុជា-ចិន ដែល

[១] អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ, លេខ០៣ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

[២] អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ, លេខ០៤ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

ជួយបង្កភាពងាយស្រួលក្នុងការធ្វើដំណើរទាំងចេញនឹងចូលតំបន់កណ្ដាលទីក្រុង។[៣]

### ១.១.១. ទីតាំងភូមិសាស្ត្រនៃតំបន់ជ្រោយចង្វារ

តំបន់ជ្រោយចង្វារនេះត្រូវបានបង្កើតឡើងនៅក្នុងរាជធានីភ្នំពេញដោយកាត់យកសង្កាត់ចំនួន ០៥ចេញពីខណ្ឌឬស្សីកែវនៃរាជធានីភ្នំពេញរួមមាន សង្កាត់ព្រែកលាប សង្កាត់ព្រែកតាសេក សង្កាត់ជ្រោយចង្វារ សង្កាត់បាក់ខែង និងសង្កាត់កោះដាច់។ ព្រំប្រទល់រដ្ឋបាលខណ្ឌជ្រោយចង្វារត្រូវបានកំណត់ដូចមានចែងក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។[៤] ទីតាំងសាលាខណ្ឌជ្រោយចង្វារត្រូវស្ថិតនៅសង្កាត់ព្រែកលាប។[៥] បំបែកចេញពីខណ្ឌឬស្សីកែវ ទីតាំងសាលាខណ្ឌជ្រោយចង្វារស្ថិតនៅសាលាសង្កាត់ព្រែកលៀប។ នៅក្នុងតំបន់ជ្រោយចង្វារនេះក៏មាននូវលក្ខណៈពិសេសជាងគេ គឺមានអាកាសធាតុល្អដោយសារមានទន្លេ ២អមសងខាង ហើយក៏មានការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជាស្ពាន និងផ្លូវធំៗខ្វាត់ខ្វែងជាច្រើនដែលជួយសម្រួលដល់ការធ្វើដំណើរចេញចូលពីខេត្តមកកាន់រាជធានីភ្នំពេញ។ ហើយចំណែកឯផ្លូវជាតិលេខ៦អាវិញ គឺជាបណ្ដាញគមនាគមន៍ដ៏សំខាន់នៅក្នុងតំបន់ជ្រោយចង្វារដែលបានតភ្ជាប់ជាមួយបណ្ដាខេត្តនានាដូចជា ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាមជាដើម។

### ១.១.២. ស្ថានភាពប្រជាសាស្ត្រ

ខណ្ឌជ្រោយចង្វារមានចំនួនប្រជាជនចំនួន ៧០២៩០នាក់នៅក្នុងឆ្នាំ២០២១ហើយក្នុងចំណោមនោះ៤៨ភាគរយជាបុរស។ សម្រាប់អ្នកវិនិយោគលើអចលនទ្រព្យគេប្រើប្រាស់ទិន្នន័យប្រជាសាស្ត្រនេះដើម្បីថ្លឹងថ្លែងការវិនិយោគថាតើប្រភេទអចលនទ្រព្យ និងទីតាំងភូមិសាស្ត្រមួយណាគួរវិនិយោគហើយ និងមានមនុស្សចូលចិត្តទៅរស់នៅច្រើននាពេលខាងមុខ។ យ៉ាងណាមិញនៅក្នុងការអភិវឌ្ឍតំបន់ជ្រោយចង្វារដោយក្រុមហ៊ុនអូស៊ីអាយស៊ី ដែលស្ថិតនៅផ្លូវជាតិលេខ៦អាក៏មានផលប៉ះពាល់ដល់ប្រជាពលរដ្ឋមួយចំនួនផងដែរ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះការអភិវឌ្ឍតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី ក៏កំពុងតែដំណើរការទៅមុខយ៉ាងរលូនហើយក៏បានដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋក៏ជិតបញ្ចប់ដែរ។ ម្យ៉ាងវិញទៀតនោះអគ្គនាយករបស់ក្រុមហ៊ុន អូស៊ីអាយស៊ី បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាជាមួយ និងប្រជាជនដែលទទួលរងនូវផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ហើយអគ្គនាយករបស់ក្រុមហ៊ុន អូស៊ីអាយស៊ី ក៏បានសាងសង់នូវទីកន្លែងរស់នៅដ៏សមរម្យសម្រាប់ប្រជាពលរដ្ឋថែមទៀតផង។ អគ្គនាយករបស់ក្រុមហ៊ុន អូស៊ីអាយស៊ី សង្ឃឹមថាតាមរយៈការអភិវឌ្ឍមួយនេះ និងធ្វើឱ្យជីវភាពប្រជាជនដែលរស់នៅទីនោះ និងមានការផ្លាស់ប្ដូរពី

[៣] គេហទំព័រ https://www.realestate.com.kh/km/news/morgan-enmaison-new-mixed-use-development-in-chroy-chang-var/ ដកស្រង់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣

[៤] អនុក្រឹត្យស្ដីពី ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ, លេខ ៥៧៧ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣, មាត្រា១

[៥] អនុក្រឹត្យស្ដីពី ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ, លេខ ៥៧៧ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣, មាត្រា២

ការប្រកបរបរកសិករ ទៅជាអាជីវករដែលមានកន្លែងលក់ដូរសមរម្យ។

## ១.២. មូលហេតុដែលនាំឱ្យមានការរៀបចំតំបន់ជ្រោយចង្វារ

បុព្វហេតុនៃការរៀបចំទៅតាមតំបន់នីមួយៗចាំបាច់ត្រូវធ្វើឡើងប្រកបដោយសនិទានកម្មពេល គឺមានការគិតគូរយ៉ាងហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។ ដូច្នេះក្រុងមួយកើតឡើងពុំមែនដោយសារកត្តាចៃដន្យទេពោល គឺកើតឡើងដោយសារតែមានមូលហេតុជំរុញពីក្រោយយ៉ាងច្រើនដូចជា កំណើនប្រជាជន ភាពក្រីក្រ ស្តង់ដារនៃការរស់នៅ និងការដាក់សម្ពាធបរិស្ថានជាដើម។ ដោយសារតែមានការវិវត្តនៃការអភិវឌ្ឍប្រទេសឥតឈប់ឈរបាននាំមកនូវការផ្លាស់ប្តូរ និងរីកចម្រើនយ៉ាងខ្លាំងក្លានៃបរិបទការរស់នៅរបស់មនុស្សពីមួយជំនាន់ទៅមួយជំនាន់។ ម្យ៉ាងទៀតដំណើរនៃការវិវត្តនេះភាពជឿនលឿនល្អប្រសើរ ក៏ដូចជាផ្តល់ភាពងាយស្រួលដល់ការរស់នៅរបស់មនុស្សជាតិ និងធ្វើឱ្យមានគុណភាពនៃការរស់នៅ។ ទន្ទឹម និងការវិវត្តនេះវាក៏ចោទជាបញ្ហាជាច្រើនដែលអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងរដ្ឋត្រូវតែដោះស្រាយ។ ដូច្នេះហើយដើម្បីធ្វើការដោះស្រាយនូវក្នុងចំណោទបញ្ហាទាំងអស់នោះ គឺរដ្ឋត្រូវតែមាននូវការរៀបចំទីក្រុងទៅតាមតំបន់នីមួយៗចំណែកឯការរៀបចំនោះ គឺត្រូវធ្វើឡើងដោយសិក្សាអំពីទ្រឹស្តីសំខាន់ៗ ឬវិធានដែលស្តីអំពីនគរូបនីយកម្ម ក៏ដូចជាផ្អែកទៅលើមូលដ្ឋានគ្រឹះ ចំណេះដឹង និងបទពិសោធន៍ទើបធ្វើឱ្យប្រទេសជាតិទទួលបាននូវភាពរីកចម្រើនលើគ្រប់វិស័យ។

### ១.២.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុងចំនួន ០៣សំខាន់គឺ៖

- កំណើនប្រជាជនជាលក្ខណៈធម្មជាតិ
- កំណើនដោយសារមានចំណាកស្រុកពីជនបទ
- និងកំណើនដោយសារការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី។

កំណើនប្រជាជនដែលនៅក្នុងស្រុកជាលក្ខណៈធម្មជាតិបាននាំឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃកំណើនប្រជាជន។ ចំណែកកំណើនដែលមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទគ្រាន់តែជាធាតុបន្ទាប់បន្សំប៉ុណ្ណោះ។

❖ **កំណើនប្រជាជននៅថ្ងៃអនាគត**

ចំនួនប្រជាជនពិភពលោក បានកើនឡើងដល់ចំនួន ៦,១៣ន់លាននាក់ក្នុងពាក់កណ្តាលឆ្នាំ២០០០ទៅហើយដោយឡែកបច្ចុប្បន្នកំពុងកើនឡើងជាមធ្យមចំនួន ៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខចំនួនប្រជាជនពិភពលោក និងមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងចន្លោះពីចំនួន ៧,៩ ទៅ ១០,៩ពាន់លាននាក់។ បើទោះបីជាមានប្រទេសមួយចំនួនបានលេចចេញនូវអត្ថិភាពនៃអត្រាមរណៈភាពខ្ពស់ដោយសារតែជំងឺអេដស៍ក៏ដោយក៏កំណើនប្រជាជននៅតែមានការកើនឡើងខ្ពស់ដ៏ដែល។ យ៉ាងណាមិញបើចំនួនប្រជាជន

នៅក្នុងប្រទេសអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ គឺមិនត្រូវគេរំពឹងថា និងកើនឡើងក្នុងរយៈពេល ៥០ឆ្នាំខាងមុខឡើយដោយសារតែកម្រិតនៅក្នុងការមានកូនត្រូវបានគេដាក់ឱ្យស្ថិតក្រោមកម្រិតកំណត់។ ផ្ទុយទៅវិញចំនួនប្រជាជនដែលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានព្យាករណ៍ថា និងកើនឡើង ៤,៩ពាន់លាននាក់។ ហើយនៅក្នុងឆ្នាំ២០០០ និងកើនឡើងដល់ ៨,២លាននាក់ក្នុងឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះត្រូវបានគេរំពឹងថា និងកើនឡើងក្នុងចំណោមក្រុមប្រទេសអភិវឌ្ឍន៍ចំនួន ៤៨ប្រទេសដែលចំនួនប្រជាជនរបស់ពួកគេត្រូវបានរំពឹងថា និងកើនឡើងក្នុងបីដងទៅ ៥០ឆ្នាំខាងមុខ។

ចំណែកឯអន្តោប្រវេសន៍អន្តរជាតិត្រូវបានព្យាករណ៍ថា និងមានកំណើនដងស៊ីតេប្រជាជនខ្ពស់នៅក្នុងសតវត្សទី២១នេះផងដែរ។[៦]

### ១.២.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពជនក្រីក្រ គឺមានការលំបាកនៅក្នុងការកំណត់ណាស់ប៉ុន្តែជាទូទៅភាពក្រីក្រសម្តៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញគ្រប់គ្រាន់។ ដែលជារួមមកប្រទេសភាគច្រើន គឺត្រូវបានគេកំណត់អំពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាបដែលពួកគេមិនអាចចាយវាយបានគ្រប់គ្រាន់នៅក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារធនធានទឹក អគ្គិសនី អនាម័យ សុខមាលភាពសង្គម គឺនូវមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ ចំពោះការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលមួយរូបៗពីព្រោះតែមានបញ្ហាផ្សេងៗដូចជាចំនួនឧក្រិដ្ឋកម្មអំពើហឹង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមដែលមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើយ ដែលជាធម្មតាអ្នកទទួលបាននូវប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ ហើយយ៉ាងហោចណាស់មានជាង ២០ភាគរយនៃចំនួនប្រជាជននៅក្នុងពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រហើយ ៩០ភាគរយក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[៧]

### ១.២.៣. តម្រូវការចាំបាច់នៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាព គឺជាកត្តាចម្បងដែលត្រូវបានគេគិតគូរនៅពេលមានការពិភាក្សាជុំវិញការជំរុញឱ្យមានការរៀបចំទីក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញឱ្យមនុស្សមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ប្រជាជននៅជនបទនៅតែចង់ចូលមករស់នៅក្នុងទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ជាកត្តាជំរុញចំណាកស្រុកដោយតែ

[៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៦

[៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៧

ពេលខ្លះការងារនៅតាមជនបទនៅមានកម្រិតដូច្នេះទោះជាទទួលបាននូវប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តធ្វើចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះនៅទីក្រុងបានប្រមូលផ្តុំនូវកត្តាសង្គមដូចជា នយោបាយល្អប្រសើរខណៈពេលសេវាសុខាភិបាល និងការអប់រំមានសម្បូរបែប គឺរឹតតែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។ ដូចនេះហើយបានជាទីក្រុង គឺជាមុខសញ្ញាមួយនៃការធ្វើចំណាកស្រុកមកពីគ្រប់ទិសទីចូលមកក្នុងក្រុងទាំងនេះក៏ជាបញ្ហាចោទមួយយ៉ាងសំខាន់ដែលទីក្រុងត្រូវតែដោះស្រាយ។[៤]

### ១.២.៤. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធ និងវិស័យបរិស្ថាន គឺកង្វះដីសម្រាប់ធ្វើការបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ហើយក្នុងករណីនេះកើតមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានមកពីដូនតាឪពុកម្តាយរបស់ខ្លួន គឺត្រូវបានពួកគេចែកមកឱ្យកូនៗអស់។ ហើយចំណែកឯផ្ទៃដីដែលនៅសល់នោះគឺវាមានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីវជាតិទៀតផង។ ប្រសិនបើយើងក្រឡេកមើលទៅមួយជ្រុងទៀតចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយប៉ុន្តែ គាត់បែរជានៅមានការខ្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ។ ករណីនេះភាគច្រើន គឺកើតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់មេគ្គងក្រោម។ ហើយបញ្ហាខាងលើនេះបណ្តាលឱ្យមានការធ្វើចំណាកស្រុកទៅកាន់ទីក្រុង។[៥]

## ១.៣. ការអភិវឌ្ឍតាមវិស័យ

ជាទូទៅមុន និងបង្កើតនូវគម្រោងអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានមួយអ្នកបង្កើតតែងតែសិក្សាបញ្ហាដូចជាស្ថានភាពសេដ្ឋកិច្ច ស្ថានភាពសង្គមកិច្ច និងស្ថានភាពផ្សេងៗទៀតជាចាំបាច់ព្រោះវាជាមូលហេតុដ៏សំខាន់អំពីស្ថានភាពពិតប្រាកដតម្រូវការពិតប្រាកដដើម្បីឈានទៅរកការបង្កើតនូវគម្រោងនោះបានសម្រេច។

### ១.៣.១. វិស័យសេដ្ឋកិច្ចនិងវិស័យសង្គមកិច្ច

#### ក. វិស័យសេដ្ឋកិច្ច

តំបន់ជ្រោយចង្វារនេះដែលពីមុនជា ទីវាលប្រែក្លាយទៅជាតំបន់មួយដែលអភិវឌ្ឍន៍ខ្លាំងនៅក្នុងរយៈពេលមួយទស្សវត្សរ៍តំបន់ជ្រោយចង្វារក៏បានប្រែក្លាយខ្លួនពីតំបន់វាលស្មើតែគ្មានអ្វីសោះទៅជាតំបន់ដែលកំពុងតែមានការអភិវឌ្ឍយ៉ាងខ្លាំងនៅក្នុងរាជធានីភ្នំពេញដោយសារតែមានការប្រកបអាជីវកម្មផ្សេងៗ និងមានបដិសណ្ឋាកិច្ចដូចជា សណ្ឋាគារ និងភោគនីយដ្ឋានជាដើម។ នៅក្នុងតំបន់ជ្រោយចង្វារនៅតាមបណ្តោយផ្លូវជាតិលេខ៦អាគឺជាច្រកសេដ្ឋកិច្ចដ៏សំខាន់មួយដែលបានតភ្ជាប់ទៅកាន់បណ្តាខេត្តសំខាន់ៗហើយតំបន់នេះក៏បានប្រែក្លាយ

[៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៨

[៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី១៨

ទៅជាតារាវៈក្នុងក្រសែភ្នែករបស់វិនិយោគិន។ តំបន់នេះកំពុងតែមមាញឹកយ៉ាងខ្លាំង ក្នុងការអភិវឌ្ឍគម្រោងធំៗជាច្រើនផ្សេងទៀតដែលបានប្រែក្លាយជាតំបន់ដ៏មានប្រជាប្រិយភាពមួយទៅជាតំបន់ដ៏មានសក្តានុពលថ្មីមួយក្នុងការអភិវឌ្ឍនានា។ មូលហេតុដែលជំរុញឱ្យអ្នកវិនិយោគងាកមកអភិវឌ្ឍន៍នៅតំបន់ជ្រោយចង្វារព្រោះតំបន់មួយនេះមានភាពរីកចម្រើនយ៉ាងខ្លាំងដែលមានបរិយាកាសដ៏ល្អបរិសុទ្ធប្រសព្វគ្នារវាងទន្លេមេគ្គង និងទន្លេសាបដែលមានសណ្ឋានដីធំទូលាយ អំណោយផលល្អប្រសើរ គួបផ្សំ និងហេដ្ឋារចនាសម្ព័ន្ធស្ពានថ្មល់មានលក្ខណៈធំទូលាយ ព្រមទាំងស្ថានភាពចរាចរណ៍មិនកកស្ទះប្រសើរជាងតំបន់កណ្ដាលទីក្រុងផងដែរ។ តំបន់ជ្រោយចង្វារកំពុងតែអភិវឌ្ឍន៍ខ្លាំងខ្លាតតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃដែល និងកំពុងតែរីកដុះដាលទៅដោយអគារខ្ពស់ៗ ផ្សារទំនើបធំៗ ធនាគារ សាលារៀន មន្ទីរពេទ្យ ហាងទំនិញ ភោគនីយដ្ឋានជាច្រើនបានក្លាយជាទីតាំងប្រជុំជនអំណោយផលទៅដល់ការធ្វើអាជីវកម្ម និងរស់នៅជាពិសេសគឺតំបន់ព្រែកលាបតែម្ដង។[១០] ជាពិសេសតំបន់ជ្រោយចង្វារនេះក៏មានគម្រោងអភិវឌ្ឍន៍ធំៗមួយចំនួនដែលមាននៅក្នុងកម្ពុជាហើយគម្រោងមួយនៅក្នុងចំណោមនោះ គឺទីក្រុងរណបជ្រោយចង្វារដែលអភិវឌ្ឍន៍ដោយក្រុមហ៊ុនវិនិយោគ អូស៊ីអាយស៊ី ជាមួយទឹកប្រាក់ ១៦ពាន់លានដុល្លារគម្រោងនេះលាតសន្ធឹងលើផ្ទៃដី ៣០០ហិកតា។ នៅក្នុងគម្រោងនេះដែរមានរួមបញ្ចូលទាំងរោងចក្រថាមពលអគ្គិសនី ផ្សារទំនើប និងមជ្ឈមណ្ឌលតាំងពិពរណ៍បរិក្ខារកីឡាក៏ដូចជាអាគាររដ្ឋាភិបាល និងសាលារៀន។

លើសពីនេះ តំបន់ជ្រោយចង្វារក៏កំពុងក្លាយជាតំបន់លំនៅដ្ឋានបែបបុរីផងដែរ។ បុរីទាំងអស់នេះមានការពេញនិយមពីសំណាក់ប្រជាពលរដ្ឋខ្មែរដែលមានចំណូលទាប និងមធ្យម។ បើនិយាយអំពីតំបន់ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍលំនៅដ្ឋានវិញតំបន់ជ្រោយចង្វារនេះ គឺត្រូវបានអ្នកជំនាញ និងអ្នកអភិវឌ្ឍន៍អចលនទ្រព្យជាច្រើនបានអះអាងដូចគ្នាថា គឺជាទីតាំងមួយដែលអំណោយផលបំផុតធៀប និងតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញ។ ជាក់ស្ដែងបើតាមបណ្ដោយផ្លូវជាតិលេខ៦អា គឺមានគម្រោងបុរីលំនៅដ្ឋានរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ធំៗបាន និងកំពុងបុកគ្រឹះសាងសង់គម្រោងរបស់ខ្លួនបន្តបន្ទាប់នៅតំបន់នោះ។ នៅក្នុងតំបន់ផ្លូវជាតិលេខ៦អានេះមិនត្រឹមតែកំពុងជាមេដែកសម្រាប់ទាក់ទាញការវិនិយោគគម្រោងបែបបុរីលំនៅដ្ឋានតែប៉ុណ្ណោះនោះទេតែក៏មានគម្រោងធំៗដូចជាទីក្រុងរណបជ្រោយចង្វាររបស់ក្រុមហ៊ុន អូស៊ីអាយស៊ី កំពុងតែមានសន្ទុះអភិវឌ្ឍន៍គួឱ្យកត់សម្គាល់។[១១]

[១០] គេហទំព័រ https://propertyarea.asia/archives/451f47 ដកស្រង់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣

[១១] គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/ ដកស្រង់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣

### ខ. វិស័យសង្គមកិច្ច

រៀបចំគោលនយោបាយ និងដឹកនាំគ្រប់គ្រងរាល់សេវាសង្គមរបស់រដ្ឋដើម្បីជួយដល់ប្រភេទជនដែលងាយរងគ្រោះ និងជនក្រីក្រ ជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ និងជនរស់នៅតាមចិញ្ចើមថ្នល់ ជួយដល់កុមារកំព្រាកុមារនៅតាមចិញ្ចើមថ្នល់ ស្រីរកស៊ីផ្លូវភេទ ជនដែលផ្ទុកមេរោគហ៊ីវ ឬអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម។ រៀបចំគោលនយោបាយស្តីពីគ្រួសារជនចាស់ជរា រៀបចំលិខិតបទដ្ឋាន និងគ្រប់គ្រងការងារសុំកូនទៅចិញ្ចឹមក្នុង និងក្រៅប្រទេស។ រៀបចំសេវាសង្គមកិច្ចដើម្បីថែរក្សាការពារ និងអប់រំកុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរដោយអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល។ ការរៀបចំគោលការណ៍គាំពារជនពិការអនុវត្តការងារស្តារលទ្ធភាពពលកម្មបង្កលក្ខណៈខាងជីវភាពរស់នៅទៅដល់ជនពិការគ្រប់ប្រភេទ។ សហការជាមួយស្ថាប័នដែលពាក់ព័ន្ធ និងចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់ អំពើពេស្យាចារ្យ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទទៅលើកុមារ ការប្រយុទ្ធប្រឆាំង និងជំងឺអេដស៍។ សហការជាស្ថាប័នពាក់ព័ន្ធជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗដូចជា គ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀតជាដើម។ បានសហការជាមួយស្ថាប័ន និងអង្គការដែលពាក់ព័ន្ធក្នុងការអនុវត្តសិទ្ធិកុមារ។ ការគ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការតាមការកំណត់នៃច្បាប់ស្តីអំពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ វិធានការគ្រប់គ្រងរបបធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញភារកិច្ច និងដល់កូនអ្នកនៅក្នុងបន្ទុក។ ដឹកនាំគ្រប់គ្រង និងសហការដៃគូរជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិទៅលើវិស័យសង្គមកិច្ច ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញការណែនាំ និងការផ្តល់សេវាសង្គមកិច្ច។ បំផុសការចូលរួមក្នុងសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌សហគមន៍មូលដ្ឋានក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានា ដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ។

### ១.៣.២. វិស័យទេសចរណ៍

តំបន់ជ្រោយចង្វារក៏មាននូវតំបន់ទេសចរណ៍ដែលមានការអភិវឌ្ឍមួយចំនួនផងដែរ រួមមានដូចជាស្ពានជ្រោយចង្វារ វិមានឈ្នះៗ កោះដាច់ និងសួនសត្វសាហ្វារីវើដភ្នំផែនជាដើម។

- **ស្ពានជ្រោយចង្វារ** ស្ពាននេះត្រូវបានគេស្គាល់ថាជាស្ពានមិត្តភាព កម្ពុជា-ជប៉ុន ដែលជាស្ពានល្បីល្បាញជាងគេនៅតំបន់ជ្រោយចង្វារ។ ស្ពាននេះបានសាងសង់កាត់ទន្លេមេគ្គង និងត្រូវបានសាងសង់ឡើងវិញក្រោមជំនួយឧបត្ថម្ភរបស់ជប៉ុននៅដើមទសវត្សរ៍ឆ្នាំ១៩៦០។ ហើយដោយសារតែត្រូវបានរងការបំផ្លាញដោយការទម្លាក់គ្រាប់ និងមានការបំផ្លិចបំផ្លាញដោយ

ខ្មែរក្រហមក្នុងសម័យសង្គ្រាមហើយស្ពាននេះ គឺបានបិទមិនឱ្យប្រើប្រាស់រហូតដល់ត្រូវបាន បានជួសជុល និងបើកឱ្យដំណើរការឡើងវិញនៅឆ្នាំ១៩៩០។

- **វិមានឈ្នះឈ្នះ** វិមាននេះ គឺជាវិមានមួយដែលត្រូវបានសាងសង់ឡើងដើម្បីការចងចាំអំពីការតស៊ូរាល់សកម្មភាព និងភាពជោគជ័យរបស់ប្រទេសកម្ពុជាដែលទទួលបានក្រោយពីការផ្តួលរំលំរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ហើយវិមានមួយនេះក៏បានប្រែក្លាយខ្លួនទៅជាតំបន់ទេសចរណ៍ថ្មីមួយនៅក្នុងទីក្រុងភ្នំពេញ។ លក្ខណៈសំខាន់នៃវិមាននេះ គឺមានកម្ពស់រហូតដល់ទៅ ៥៤ម៉ែត្រហើយបានលាតសន្ធឹងលើផ្ទៃដីលើសពី ៨ហិកតាហើយវិមាននេះដែរក៏មាននូវ រូបភាពរោងភាពយន្ត និងបណ្ណាល័យផងដែរ។
- **កោះដាច់** គឺជាកន្លែងមួយដ៏មានប្រជាប្រិយមួយក្បែររាជធានីភ្នំពេញ។ ហើយក៏មានកោះដ៏ស្រស់ស្អាតនេះស្ថិតនៅលើដងទន្លេមេគង្គ និងជាតំបន់មួយដែលមានឈ្មោះដ៏ល្បីជាមួយផលិតផលសូត្រ និងតម្បាញ។ ដោយសារតែមានទីតាំងនៅដាច់ឆ្ងាយពីគេទាំងទេសចរណ៍ជាតិ និងអន្តរជាតិតែងតែទៅលេងកោះនេះដើម្បីលម្ហែកាយជាមួយភាពស្ងប់ស្ងាត់។ កោះនេះក៏ជាកន្លែងដែលអាចនូវទិញផលិតផលសូត្រ ចម្លាក់ឈើ ក្អម និងផលិតផលសិប្បកម្មដ៏ទៃផ្សេងៗទៀត។
- **សួនសត្វសាហ្វារីវើដភ្នំពេញ** សួននេះជាសួនសត្វដ៏ធំជាងគេនៅប្រទេសកម្ពុជាមានសត្វជាង ៨០០ក្បាលដែលរួមមានសត្វក្តាន់ ខ្លា និងសត្វកវែង។ មិនត្រឹមតែប៉ុណ្ណោះក៏មានសត្វសម្តែងជារៀងរាល់ថ្ងៃដែលមានការពេញនិយមបំផុតសម្រាប់អ្នកទស្សនា។[១២]

### ១.៣.៣. វិស័យគមនាគមន៍

ការអភិវឌ្ឍមួយដែលច្បាស់លាស់ គឺត្រូវបានធ្វើឡើងដោយការពង្រីកទំហំទីក្រុង។ ចំណែកឯប្រព័ន្ធគមនាគមន៍គំរូដែលរួមមានផ្លូវធ្វើដំណើរ និងហេដ្ឋារចនាសម្ព័ន្ធ។ ការធ្វើសមាហរណកម្មមួយដ៏ប្រសើរ គឺជាការអភិវឌ្ឍពីតំបន់ដែលឆ្លងកាត់ឱ្យក្លាយទៅជាតំបន់ដែលមានការអភិវឌ្ឍខ្លាំង។[១៣] នៅក្នុងតំបន់ជ្រោយចង្វារនេះក៏មាននូវការអភិវឌ្ឍប្រព័ន្ធគមនាគមន៍មួយចំនួនដែរដូចជា ស្ពានក៏ដូចជាផ្លូវថ្នល់ដែលជួយបង្កឱ្យមានភាពកាន់តែងាយស្រួលក្នុងការធ្វើដំណើរទៅវិញទៅមក របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជ្រោយចង្វារនោះហើយជាពិសេសជួយកាត់បន្ថយការកកស្ទះផងដែរ។

---

[១២] គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/ ដកស្រង់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣

[១៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី២០

- **ស្ពានជ្រោយចង្វារទី១**

ស្ពានជ្រោយចង្វារទី១ ជាស្ពានមួយដែលបានឆ្លងកាត់ទន្លេសាបមុនគេនៅកម្ពុជាដែលមានប្រវែង ៧០៩ម៉ែត្រ ស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញតភ្ជាប់ជាមួយ និងផ្លូវជាតិលេខ៦អា។ ហើយស្ពាននេះគឺត្រូវបានគេសាងសង់ឡើងនៅក្នុងឆ្នាំ១៩៦៣ នៅក្នុងសម័យសង្គមរាស្ត្រនិយមក្រោយជំនួយខាងបច្ចេកទេសរបស់រដ្ឋាភិបាលជប៉ុន ដោយសារតែមាននូវសង្គ្រាមស៊ីវិលនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ស្ពាននេះត្រូវទទួលរងនូវការខូចខាតស្ទើរតែទាំងស្រុង។ រហូតមកដល់ក្នុងឆ្នាំ១៩៩២ ស្ពាននេះត្រូវបានជួសជុលស្តារឡើងវិញក្រោយជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន។ ហើយស្ពាននេះគេបានបើកឱ្យដំណើរការសារជាថ្មីម្តងទៀតនៅក្នុងឆ្នាំ១៩៩៦ហើយបានប្រែក្លាយជាច្រករបៀងសេដ្ឋកិច្ចយ៉ាងសំខាន់ និងតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់បណ្តាខេត្តផ្សេងៗរបស់ប្រទេសកម្ពុជា។ បន្ទាប់មកស្ពានជ្រោយចង្វារទី១ត្រូវបានដាក់ឈ្មោះថា ស្ពានមិត្តភាពកម្ពុជា-ជប៉ុន ហើយស្ពាននេះក៏បានជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងជួយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចតាមរយៈការដឹកជញ្ជូនទំនិញមកកាន់ទីក្រុងភ្នំពេញ។[១៤]

- **ស្ពានជ្រោយចង្វារទី២**

ស្ពានជ្រោយចង្វារទី២ ត្រូវបានបើកការដ្ឋានសាងសង់ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលស្ពាននេះមានប្រវែង ៧១៩ម៉ែត្រដែលចំណាយពេលសាងសង់រយៈពេល ៣៨ខែព្រមទាំងបានចំណាយនូវថវិកាចំនួន ២៧.៥០០.០០០ ដុល្លារអាមេរិកដែលជាកម្ចីឥណទានរបស់រដ្ឋាភិបាលចិនហើយក្រោយមកក៏បានដាក់ឈ្មោះថា ស្ពានមិត្តភាពកម្ពុជា-ចិន។[១៥]

- **ផ្លូវជាតិលេខ៦អា**

ផ្លូវជាតិនេះ គឺជាផ្លូវជាតិដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា និងបានតភ្ជាប់ពីរាជធានីភ្នំពេញភ្ជាប់ជាមួយនិងបណ្តាខេត្តផ្សេងៗដូចជា ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងតំបន់ទេសចរណ៍ខេត្តសៀមរាបដែលមានប្រវែង៣១២ម៉ែត្រ។

- **ផ្លូវចំនួន២ខ្សែនៅសង្កាត់ជ្រោយចង្វារ និងសង្កាត់ព្រែកតាសេក**

ក្នុងឆ្នាំ២០២៣រាជរដ្ឋាភិបាលខណ្ឌជ្រោយចង្វារបានរៀបចំស្ថាបនាផ្លូវចំនួន ០២ខ្សែនេះដែលស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ការធ្វើដំណើររបស់ពលរដ្ឋ។ ផ្លូវទាំង២ខ្សែនេះ គឺតភ្ជាប់ពីផ្លូវជាតិលេខ៦អាឆ្ពោះទៅកាន់មហាវិថីឈ្នះឈ្នះ ដែលមានរយៈប្រវែង

[១៤] គេហទំព័រ kleykley.sabay.com.kh (https://kleykley.sabay.com.kh/article/1248065) ដកស្រង់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣

[១៥] គេហទំព័រ FRESH NEWS (https://m.freshnewsasia.com/index.php/en/11318-2015-10-16-08-45-32.html) ដកស្រង់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣

ជាង ១០គីឡូម៉ែត្រក្នុងមួយខ្សែៗមានទទឹង ១៥ម៉ែត្រដែល និងសាងសង់អំពីបេតុងឆ្អឹងដែក និងមានចិញ្ចើមផ្លូវ២ម៉ែត្រនៅសងខាង។

គួរបញ្ជាក់ផងដែរថាការសាងសង់ផ្លូវទាំងពីរ និងដើរតួនាទីយ៉ាងសំខាន់ដែលជាសរសៃឈាមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្នុងតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរចំនេញពេលវេលា និងជួយកាត់បន្ថយការកកស្ទះចរាចរណ៍ផងដែរ។[១៦]

### ១.៣.៤. វិស័យដែលពាក់ព័ន្ធ

មិនត្រឹមតែប៉ុណ្ណោះនៅតំបន់ជ្រោយចង្វារនេះក្រៅពីវិស័យទាំង ៤ដែល រួមមានដូចជា វិស័យសេដ្ឋកិច្ច និងវិសយសង្គមកិច្ច វិស័យទេសចរណ៍ វិស័យគមនាគមន៍ ខាងលើក្នុងតំបន់ជ្រោយចង្វារក៏មានការអភិវឌ្ឍនូវវិស័យដែលពាក់ព័ន្ធផ្សេងៗមួយចំនួនទៀតដូចជា វិស័យសាសនា និងវិស័យអប់រំជាដើម។

- **វិស័យសាសនា**

  - **វត្តសិរីគៀនឃ្លាំង** វត្តសិរីគៀនឃ្លាំងមានឈ្មោះពេញថា "វត្តមង្គលសិរីគៀនឃ្លាំង" ដែលមនុស្សភាគច្រើនចូលចិត្តហៅវត្តមួយនេះថាជាវត្តគៀនឃ្លាំង គឺជាវត្តអារាមមួយដែលស្ថិតនៅក្នុងខណ្ឌជ្រោយចង្វាររាជធានីភ្នំពេញ។ ហើយវត្តអារាមមួយនេះ គឺមានព្រះវិហារ២ដែលព្រះវិហារថ្មីមានទីតាំងនៅខាងមុខជាប់ផ្លូវចូលខាងឆ្វេងដៃ និងព្រះវិហារបុរាណមានទីតាំងនៅខាងក្រោយជាប់ផ្លូវបេតុងជាប់ទន្លេមេគង្គ។ ព្រះវិហារបុរាណនេះត្រូវបានក៏សាងឡើងនៅឆ្នាំ ព.ស ២៤៧២ ត្រូវនឹង គ.ស ១៩២៨។[១៧]
  - **វត្តប្រជុំសាគរ** ដែលស្ថិតនៅទឹកដីខណ្ឌជ្រោយចង្វារត្រើយខាងកើតវត្តប្រជុំសាគរនេះ គឺជាវត្តមួយដែលមានសំណង់ព្រះវិហាបុរាណ និងដើមពោធិមួយដើមធំដែលមានប្រភពមកពីប្រទេសស្រីលង្កាតាំងពីសម័យសម្តេចព្រះមហាសង្ឃរាជទី១ នៃគណៈមហានិកាយនៃប្រទេសកម្ពុជានិលទៀងឆ្នាំ១៨២៤-១៩១៣ ហើយវត្តប្រជុំសាគរបានកសាងឡើងនៅក្នុងឆ្នាំមមី ចត្វាស័ក ព.ស២៤២៤ គ.ស១៨៨០។[១៨]
  - **វត្តសំពៅត្រៃល័ក្សនិងវត្តពោធិយារាម** ដែលវត្តទាំងពីរនេះ គឺមានទីតាំងនៅខណ្ឌជ្រោយចង្វារសង្កាត់ជ្រោយចង្វាររាជធានីភ្នំពេញ។

---

[១៦] គេហទំព័រ https://cambodiapropertyreport.com/article/4814 ដកស្រង់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣

[១៧] គេហទំព័រ news.sabay.com.kh (https://news.sabay.com.kh/article/1300446) ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

[១៨] គេហទំព័រ https://social.sabay.com.kh/article/1309114 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

❖ **វិស័យអប់រំ**

តំបន់ជ្រោយចង្វារមាននូវគ្រឹះស្ថានអប់រំជាតិ និងអន្តរជាតិមួយចំនួនដូចជាៈ

- បឋមសិក្សាវត្តសិរីមង្គលគៀនឃ្លាំង
- វិទ្យាល័យជាស៊ីមជ្រោយចង្វារ
- សកលវិទ្យាល័យខេមតិច
- សកលវិទ្យាល័យន័រតុន
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- សាលាអាមេរិកកាំង
- និងសាលាអន្តរជាតិអូស្ត្រាលីភ្នំពេញជាដើម។

## ១.៤. ការថែរក្សាបរិស្ថានចំពោះការបំពុលនាំ៥

### ១.៤.១. ការបំពុលទឹក

❖ **ប្រភពនៃការបំពុលទឹក**

ការបំពុលទឹក គឺជាសកម្មភាពមួយដែលធ្វើអោយប្រភពទឹកដូចជាសមុទ្រ ទន្លេ បឹងបួ ស្ទឹង ព្រែក កង្វក់គ្មានអនាម័យជាដើម។ល។ ហើយប្រភពនៃការបំពុលទឹកមានពីរប្រភេទ គឺប្រភពបំពុលចំណុច និង ប្រភពបំពុលរាយប៉ាយ។[១៩]

- **ប្រភពបំពុលចំណុច** គឺជាប្រភពដែលបញ្ចេញសំណល់ចូលទៅក្នុងបរិស្ថានតាមរយៈបំពង់បង្ហូរលូ ឬប្រឡាយពីទីតាំងច្បាស់លាស់មួយដូចជា រោងចក្រឧស្សាហកម្ម ឬរោងចក្រសំអាតទឹកលូសម្អុយជាដើម។
- **ប្រភពបំពុលរាយប៉ាយ** គឺជាប្រភពមួយដែលបង្កឱ្យមានការបំពុលដោយសារធាតុបំពុល គីមីដែលហូរធ្លាក់ចូលទៅក្នុងទឹកនៅលើផ្ទៃដីនៃតំបន់ដ៏ធំមួយ។[២០] ការបំពុលទឹកភាគច្រើន គឺបណ្តាលមកពីសំណល់ចេញពីរោងចក្រឧស្សាហកម្ម កសិកម្ម និងសំណល់តាមផ្ទះដែល ផ្តល់ប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វក៏ដូចជាគុណភាពបរិស្ថាននៃប្រភព ទឹកទាំងមូល។

❖ **ផលប៉ះពាល់នៃការបំពុលទឹក**

ការបំពុលទឹកអាចបំផ្លាញដល់អាយុជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិដែលការបំពុលទឹកនេះអាច

[១៩] គេហទំព័រ https://cambo-report.com/article/96 ដកស្រង់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣

[២០] គេហទំព័រ https://www.khsearch.com/qna/11287 ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

ប៉ះពាល់ដល់ដំណាំដែលប្រើប្រាស់ប្រភពទឹកនោះផងដែរធ្វើអោយខូច ឬអាចប៉ះពាល់នៅពេលដែលមនុស្សបរិភោគបន្លែដែលមានជាតិពុលនោះ។ ចំពោះការបំពុលទឹកនេះដែរវាក៏ធ្វើអោយមនុស្សទទួលរងនូវការឆ្លងជំងឺមួយចំនួនដូចជា ជំងឺឈឺត្រចៀក ភ្នែកឡើងពណ៌ផ្កាឈូក ជំងឺផ្លូវដង្ហើម ក៏ដូចជាជំងឺរលាក់ថ្លើម ដែលទាំងអស់នេះអាចបណ្តាលឱ្យមនុស្សស្លាប់បាន។

❖ **វិធានការក្នុងការកាត់បន្ថយការបំពុលទឹក**

- ប្រើប្រាស់ទឹកក្នុងការសន្សំសំចៃខ្ពស់
- មិនត្រូវបោះចោលកាកសំណល់ ទាំងឡាយណាដែលបណ្តាលឱ្យមានការកង្វក់ទឹក
- មិនត្រូវប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីគីមី ដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
- អប់រំប្រជាជនឱ្យបានយល់ដឹងច្បាស់អំពីបញ្ហាបរិស្ថាន និងតម្លៃនៃការខូចខាត និងផលពិបាកតាមរយៈការឃោសនាគ្រប់រូបភាព បញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធី សិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ
- ក្រសួងពាក់ព័ន្ធត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថាន និងចេះគ្រប់គ្រងនិងតាមដានជាតិពុលទាំងឡាយណាដែលបណ្តាលឱ្យមានកង្វក់ទឹកហើយ និងបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលក្នុងទឹកជាដើម
- ណែនាំអប់រំដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីយដ្ឋាន ភោគនីយដ្ឋានឱ្យធ្វើនូវអាងសំអាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលទៅក្នុងទឹក
- បង្កើតក្រុមចុះត្រួតពិនិត្យ និងដាក់ពិន័យចំពោះអ្នកទាំងឡាយណាធ្វើឱ្យមានកង្វក់ទឹក

គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលជាសម្ថកិច្ចរបស់ក្រសួងបរិស្ថាន។[២១] ទន្ទឹមជាមួយគ្នានេះផងដែរ គឺត្រូវបានហាមឃាត់ដាច់ខាតរាល់ការចាក់ចោលក៏ដូចជាការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតស្តង់ដារនៃការបញ្ចេញសំណល់រាវ។[២២]

## ១.៤.២. ការបំពុលខ្យល់

❖ **ប្រភពនៃការបំពុលខ្យល់**

ប្រភពនៃការបំពុលខ្យល់មាន ២ប្រភេទ គឺប្រភពចេញពីធម្មជាតិ និងប្រភពចេញពីមនុស្ស។

[២១] អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា១៨
[២២] អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៦

➢ **ប្រភពចេញពីធម្មជាតិ**

- ការពុករលួយរុក្ខជាតិជាប្រភពប្រតិកម្មសារធាតុស៊ុលផូក្នុងអាកាស ភ្លើងឆេះព្រៃបង្កើតបានជាពពកផ្សែងគ្របដណ្ដប់ទ្វីប
- ព្យុះនៅតំបន់ស្ងួតហែងបង្កើតបានជាពពកធូលីរាប់លានតោនដឹកនាំចូលទៅក្នុងអាកាស
- អំបិលភាយចេញពីសមុទ្រ លំអងផ្កា វីរុស បាក់តេរី ស្ប៉ដែលអាចបង្កឱ្យមានគ្រោះថ្នាក់។

➢ **ប្រភពចេញពីសកម្មភាពរបស់មនុស្ស**

- តំបន់ឧស្សាហកម្មរោងចក្រថាមពលអគ្គិសនីបានបញ្ចេញ ថាមពលគីមីពុលយ៉ាងខ្លាំងចូលទៅក្នុងខ្យល់អាកាស
- ការព្យួររាស់ដីគម្រោងសាងសង់សំណង់អាគារធំៗ និងអាជីវកម្មរ៉ែក៏បណ្ដាលឱ្យមានធូលីចូលទៅក្នុងអាកាសដែរយានយន្តគ្រប់ប្រភេទបានបញ្ចេញផ្សែងធូលីផងដែរ។[២៣]

❖ **វិធានការក្នុងការទប់ស្កាត់ការបំពុលខ្យល់**

ក្រសួងបរិស្ថានណែនាំពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ ដើម្បីធានាគុណភាពខ្យល់ឱ្យល្អប្រសើរដូចជា៖

- ត្រូវចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃ និងការដុតសំរាមសំណល់រឹងនៅតាមទីចំហការឆេះនៅតាមទីលានចាក់សំណល់
- ត្រូវចាត់វិធានការនៅក្នុងការទប់ស្កាត់ការហុយនូវធូលីពីការដ្ឋានសំណង់ និងការដ្ឋានកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងធូលីហុយនៅតាមដងផ្លូវ
- ការធ្វើសំអាតអនាម័យនៅតាមដងផ្លូវ និងទីសាធារណៈ
- អប់រំប្រជាពលរដ្ឋកុំឱ្យដុតសំរាម សំណល់រឹង ការដុតស្មៅ គល់ជញ្ជ្រាំង និងសំណល់កសិកម្មផ្សេងៗ។[២៤] ម្យ៉ាងវិញទៀតដើម្បីទប់ស្កាត់ការបំពុលខ្យល់គឺត្រូវ៖
- សង់រោងចក្រឱ្យឆ្ងាយពីទីក្រុង
- ដឹកសំរាមចេញពីទីក្រុងសំអាតទីក្រុង និងបង្កើតនូវរោងចក្របំប្លែងសំរាមឱ្យទៅជារបស់ដែលអាចប្រើប្រាស់
- អប់រំចំណេះដឹងអំពីការរក្សាបរិស្ថាន

---

[២៣] គេហទំព័រ https://www.khsearch.com/qna/5637 ដកស្រង់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

[២៤] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/229877-2022-02-01-06-14-26.html ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

- ប្រើប្រាស់យានយន្តស្រពតាមបច្ចេកទេស
- ទឹកសំបូរបែប មានអនាម័យ តម្លៃទាប
- វិធានការច្បាប់ចំពោះអ្នកបំពុលខ្យល់។[២៥]

### ១.៤.៣. ការបំពុលសំឡេង

សំឡេងមានតួនាទីនៅក្នុងជីវិតមនុស្សជារៀងរាល់ថ្ងៃ។ ប្រភពនៃការបំពុលសំឡេងដែលរួមមានដូចជាការនិយាយ ភ្លេង សត្វ និងផ្សេងៗទៀតជាដើម។ នៅពេលដែលមានសំឡេងដែលមិនត្រូវការហើយមានប៉ះពាល់ដល់សកម្មភាពធម្មតាវា គឺការបំពុលដោយសំឡេង។ មនុស្សយើងមិនសូវទទួលស្គាល់សំឡេងថាវា គឺជាការបំពុលនោះទេដោយសារតែសំឡេងយើងមិនអាចមើលឃើញ ឬក៏ធុំក្លិនវាដូចជាការបំពុលទឹក ការបំពុលដី និងការបំពុលខ្យល់។[២៦]

❖ **គុណវិបត្តិនៃការបំពុលសំឡេង**

- រំខានដល់ការសិក្សារៀនសូត្រ ការរំខានដំណេក
- សោតវិញ្ញាណចុះខ្សោយ ឬមិនអាចស្តាប់លឺ (ហ៊ឹងត្រចៀក)
- ជំងឺលើសសម្ពាធឈាម
- បំផ្លាញដល់ការចងចាំ។ **ឧទាហរណ៍** ទាក់ទងជាមួយ និងការបើកការដ្ឋានសាងសង់គម្រោងធំៗដែលត្រូវប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្តដូចជា ត្រាទ័រ រថយន្តសម្រាប់ដឹកជញ្ជូនសម្ភារៈ ឧបករណ៍លាយបេតុង គ្រឿងចក្រសម្រាប់កិនបង្ហាប់ និងគ្រឿងចក្រធុនៗផ្សេងៗទៀត គឺពិតជាបង្កនូវសំឡេងរំខានយ៉ាងខ្លាំងដល់ប្រជាជនដែលរស់នៅជិតតំបន់ការដ្ឋាននោះ។ [២៧]

បើយោងតាមអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងការបំពុលដោយសំឡេងមានពីរប្រភេទគឺៈ

- **ប្រភពចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍ៈ មានយន្តហោះ នាវាដឹកជញ្ជូន គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។
- **ប្រភពអចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍ៈ មានដូចជារោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។[២៨]

---

[២៥] គេហទំព័រ https://www.khsearch.com/qna/1292 ដកស្រង់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣

[២៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី៣៨

[២៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី៣៩

[២៨] អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា៣

❖ **វិធានការទប់ស្កាត់ការបំពុលដោយសំឡេង**

ដើម្បីការពារកុំឱ្យមានការបំពុលដោយសំឡេងត្រូវមានវិធានការដូចខាងក្រោម:

- អប់រំប្រជាជនឱ្យស្គាល់ពីការរំខានដោយសំឡេង
- ត្រូវផ្សព្វផ្សាយពីផលិតផលប៉ះពាល់ នៃការរំខានដោយសំឡេងតាមប្រព័ន្ធឃោសនា និង ប្រព័ន្ធអប់រំនៅតាមសាលារៀន
- ណែនាំអប់រំដល់ម្ចាស់ឧស្សាហកម្ម សិប្បកម្មសហគ្រាស ក្រុមហ៊ុន ភោគនីយដ្ឋាន ឱ្យសង់ រោងដាក់ម៉ាស៊ីន និងធ្វើបំពង់ការពារសំឡេង ឬមានការបង្កើតគណៈកម្មការចុះត្រួតពិនិត្យ
- ត្រូវចុះតាមដាន ឧស្សាហកម្ម សិប្បកម្ម សហគ្រាស ក្រុមហ៊ុន ភោគនីយដ្ឋាន ខារ៉ាអូខេ និង លំនៅដ្ឋានណាដែលពុំដែលអនុវត្តតាមលំណែនាំនេះ
- ត្រូវដាក់ពិន័យជាបន្ទាន់ ឬអូសយកឧបករណ៍ទាំងនោះដើម្បីជាការព្រមាន
- ចំពោះលំនាំចូលទោចក្រយានយន្ត គួរដាក់កម្រិតកំណត់ខ្ពស់ដើម្បីលុបបំបាត់សូរសំឡេង
- ដើម្បីកាត់បន្ថយកម្រិតនៃសូរសំឡេងដែលមានកម្លាំងខ្ពស់ គឺត្រូវប្រើឧបករណសម្រាប់កាត់ បន្ថយនូវសូរសំឡេង
- ដើម្បីជៀសវាងការរំខានដល់អ្នកជិតខាង ក៏ដូចជាការពារសេចក្តីថ្លៃថ្នូរ និងសុជីវធម៌រស់នៅ សូមបងប្អូនដែលបានអនុវត្តខុសឆ្លងកន្លងមកកែលម្អ និងរួមចំណែកជួយការពារបរិស្ថាន
- បញ្ឈប់រាល់ការប្រើប្រាស់នូវវត្ថុយន្តជជុះដែលវាលាន់លឺសំឡេងខ្លាំងៗ ហើយងាកមកប្រើ ជាមធ្យោបាយដឹកជញ្ជូនសាធារណៈ ឬការប្រើប្រាស់កង់ ឬស៊ីក្លូ
- ជៀសវាងការស្រែកឡូឡានៅតាមគេហដ្ឋាន សាលារៀន ឬទីផ្សាធារណៈ។[២៩]

## ១.៤.៤. ការបំពុលដោយសំណល់រឹងរាវ

❖ **ប្រភពនៃការបំពុលសំណល់រឹង រាវ**

សំណល់រឹង គឺសំដៅលើសារធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភព បំពុល។ ចំណែកឯសំណល់រាវវិញ គឺសំដៅទៅលើវត្ថុរាវដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈទោះបានធ្វើប្រតិកម្ម ឬមិនបានធ្វើប្រតិកម្មក្តី។ ទន្ទឹម ជាមួយគ្នានេះផងដែរប្រភពបំពុលសំណល់ទាំងអស់នេះ គឺវាមានប្រភពមកពីលំនៅឋានផ្សេងៗអគាររដ្ឋបាល សារធារណៈមកពីទីបរិវេន មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រឹង រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬដោយមិនផ្ទាល់ក្តីដែលចូលទៅក្នុងតំបន់

[២៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី៤០

សារធារណៈ។[៣០] ម្យ៉ាងទៀតប្រភពសំណល់មានប្រភពចេញពីរោងចក្រដូចជា រោងចក្រផលិតអាគុយ ស័ង្កសី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពណ៌កំប៉ុង និងរោងចក្រផលិតក្រដាសជាដើម។ ម្យ៉ាងទៀតប្រភពសំណល់នេះ គឺចេញពីមន្ទីរពេទ្យ (សំបកថ្នាំ ម្ជុលចាក់ថ្នាំ បង់រុំរបួស) និងសំណល់ដែលនៅតាមកន្លែងសត្តឃាតផងដែរ។

❖ **វិធានការទប់ស្កាត់ការបំពុលសំណល់រឹង រាវ**

តាមប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត/ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយដោយរាប់បញ្ចូលទាំងការប្រមូល ការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចដែលពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ រាជធានីខេត្ត ក្រុងប្រកបទៅដោយប្រសិទ្ធិភាពទូទាំងប្រទេស។ ប្រកាសអន្តរក្រសួងលេខ៨០ ផ្តល់ឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ និងតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ការដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភ័ណភាព និងបរិស្ថាន ដាក់ស្លាកហាមឃាត់ចោលសំរាម និងអប់រំឱ្យមានការដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាមសំណល់រឹងបណ្តោះអាសន្នឱ្យបានសមរម្យ ដោយគ្មានការរំខានដោយចរាចរណ៍ សុខភាពសាធារណៈសោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- ប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងឱ្យបានទៀងទាត់នៅទីលានចាក់សំរាមដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ដោយមានការសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនានាត្រូវអប់រំ និងត្រូវផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណៈជនអំពីការទុកដាក់សំរាម សំណល់រឹងតាមវិធីសាស្ត្រប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវតែមានការជម្រុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន។
- មន្ទីរបរិស្ថានខេត្ត ក្រុង និងការិយាល័យបរិស្ថានស្រុកខណ្ឌត្រូវដើរតួនាទីជា សេនាធិការឱ្យអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមបង្កើតផែនការសកម្មភាពក្នុងការប្រមូល ការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន ការចាក់សំរាមក្នុងទីលានចាក់សំរាមដែល

[៣០] អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៣

ត្រូវផ្ញើរបាយការណ៍នេះទៅក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានព្រមទាំងក្រសួងដែលមានការពាក់ព័ន្ធនានាទៀតផង។[៣១]

យោងតាមអនុក្រឹត្យលេខ១១៣ដែលទទួលបានការអនុម័តកាលពីខែសីហា ឆ្នាំ២០១៥បានកំណត់អាណត្តិកាន់តែមាននូវភាពច្បាស់លាស់ និងមានភាពប្រសើរដល់រដ្ឋបាលក្រុង/ស្រុកនៅក្នុងការគ្រប់គ្រងសំរាមសំណល់រឹង។

ដោយយោងតាមអនុក្រឹត្យលេខ១១៣ នេះមានគោលបំណងដូចខាងក្រោមៈ

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកដែលពាក់ព័ន្ធនានា លើការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាមសំណល់រឹងនៅតាមទីប្រជុំជនឱ្យទៅរដ្ឋបាលរាជធានីក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារនៃការគ្រប់គ្រងនូវសំរាម ឬកាកសំណល់រឹងនៅតាមទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធិភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាមសម្រាប់សំណល់រឹងទីប្រជុំជន
- លើកកម្ពស់ការនូវយល់ដឹងសារធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។[៣២]

### **១.៤.៥. ការបំពុលដី**

ការបំពុលដី គឺជាការធ្វើឱ្យដីខូចបាត់បង់ជីវភាព និងបណ្តាលឱ្យមនុស្ស សត្វ និងរុក្ខជាតិពិបាកនៅក្នុងការរស់រានមានជីវិត ឬឈានទៅដល់ការបាត់បង់ជីវិតក៏មានដែរ។ ម្យ៉ាងវិញទៀតការបំពុលដីនេះ គឺជាបញ្ហាដ៏ធំមួយនៅលើពិភពលោកដែលបណ្តាលមកពីកត្តាផ្សេងៗជាច្រើនទៀតដែលរួមមាន៖ សកម្មភាពកសិកម្ម សកម្មភាពឧស្សាហកម្ម សកម្មភាពវិទ្យុសកម្ម និងការចោលសំណល់ផ្សេងៗ។

❖ **សកម្មភាពកសិកម្ម** ជាធម្មតាដើម្បីធ្វើស្រែចំការ ដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជា ដង្កូវ និងសត្វល្អិតជាដើម។ ការប្រើថ្នាំ និងជីសម្លាប់សត្វល្អិតជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ កសិដ្ឋានចិញ្ចឹមជ្រូកបង្កើតឱ្យ

[៣១] ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្តីពី ការគ្រប់គ្រងសំរាម និងកាកសំណល់រឹង នៅថ្នាក់ខេត្ត ក្រុង, លេខ ៨០ ប្រក.មផ-បស្ថ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣

[៣២] អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥, មាត្រា២

មាននូវលាមក និងទឹកនោមដែលបញ្ចេញនូវឧស្ម័នពុលជាច្រើនហើយជ្រាបទៅក្នុងដីធ្វើឱ្យដីទទួលរងនូវសារធាតុពុល។

❖ **សកម្មភាពឧស្សាហកម្ម** ដោយសារតែឧស្សាហកម្មដែលជាកន្លែងដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមីច្រើនការបំពុលដោយសំណល់នេះអាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់មនុស្ស និងធ្វើឱ្យការលូតលាស់យឺតជាងធម្មតា។ ឧស្សាហកម្មដែលបំពុលច្រើនជាងគេ គឺឧស្សាហកម្មផលិតក្រដាស និងផលិតចំណីអាហារ។

❖ **ការបំពុលវិទ្យុសកម្ម** ចេញពីរោងចក្រនុយក្លេអ៊ែរ ដែលមានផ្ទុកសារធាតុអ៊ុយរ៉ាញ៉ូមដើម្បីផលិតគ្រឿងអគ្គិសនីដែលអ្នកយោធាបានប្រើប្រាស់នៅក្នុងនាវាមុជទឹក និងផលិតគ្រាប់បែកដោយបន្សល់នូវសំណល់ និងបញ្ចេញកាំរស្មីថាមពលជាហេតុនាំឱ្យបង្កគ្រោះថ្នាក់ដល់សុខភាពបណ្តាលឱ្យស្លាប់ មានជំងឺមហារីក និងអាចធ្វើឱ្យគ្មានកូនឬធ្វើឱ្យទារកមានកាយសម្បទាមិនគ្រប់គ្រាន់។

❖ **ការចោលសំណល់ផ្សេងៗ** ការបោះចោលសំណល់ដូចជា ថង់ប្លាស្ទិច កាតុង ក្រដាស កែវ សំណល់សរីរាង្គសំបកដបសំបកកង់ឡានម៉ូតូជាដើម។ ហើយវត្ថុទាំងអស់នេះគឺមិនងាយរលាយនោះទេបើទោះជារលាយក៏មានរយៈពេលយូរដែរធ្វើឱ្យបរិស្ថានមិនស្រស់ស្រាយ។[៣៣]

➢ **វិធានការទប់ស្កាត់ការបំពុលដី**

- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសមណល់រឹងទៅលើដី
- ត្រូវធ្វើការរៀបចំ គ្រប់គ្រង និងត្រូវពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំទីកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ប្រកបដោយប្រសិទ្ធិភាព និងមិនប៉ះពាល់ដល់បរិស្ថាន
- ការកំណត់ប្រភេទ ឬកម្រាស់ ឬទំហំនៃថង់ប្លាស្ទិក។ អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិចបានកំណត់ហាមឃាត់ការនាំចូលការផលិតក្នុងស្រុកការប្រើប្រាស់ និងចែកចាយនូវថង់ផ្លាស្ទិកស្តើង និងមានដៃយួរគ្រប់ប្រភេទលើកលែងតែថង់ប្លាស្ទិកនោះមានកម្រាស់ចាប់ពី ០០៣មីលីម៉ែត្រឡើងទៅ និងមានរង្វាស់ទទឹងផ្ទៃកបាតខាងក្រោមចាប់ពី ២៥សង់ទីម៉ែត្រ ឬ ១០ អ៊ីងឡើងទៅ
- ធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យសាធារណៈជនទាំងអស់ចូលរួមនៅក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា

[៣៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣ ទំព័រទី២៣-២៤

- រាល់លំនៅឋាន ផ្សារទំនើប កន្លែងកំសាន្ត និងស្ថាប័នទាំងអស់ មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់រឹងដាច់ដោយឡែកពីសំណល់ផ្សេងៗ តាមគោលការណ៍របស់ក្រសួងបរិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោយបំបែក ធ្វើប្រតិកម្ម ឬបោះបង់ចោល សំណល់រឹង ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ដែលបង្កឱ្យប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។

**ឧទាហរណ៍** សំណល់អាគុយ,សំណល់ថ្មពិល, ឬសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិច។[៣៤]

[៣៤] អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិច, លេខ ១៦៨ អនក្រ.បក, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧, មាត្រា១៤

# ជំពូកទី២

# ការអភិវឌ្ឍតំបន់ព្រៃឈើ

# ( អូស៊ីអាយស៊ី២០១៧-២០២៥ )

# ជំពូកទី២

# ការអភិវឌ្ឍតំបន់ជ្រោយចង្វារ (អូស៊ីអាយស៊ី២០១៧-២០២៥)

## ២.១. សញ្ញាណទូទៅនៃតំបន់អូស៊ីអាយស៊ី

តំបន់អភិវឌ្ឍន៍ជ្រោយចង្វារ គឺជាគម្រោងដ៏ធំមួយរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី ដែលស្ថិតនៅក្នុងខណ្ឌជ្រោយចង្វារនៅក្នុងរាជធានីភ្នំពេញដែលអភិវឌ្ឍន៍ និងកំពុងសាងសង់ឡើងនៅលើផ្ទៃដីជាង ២០០ហិកតាដែលលាតសន្ធឹងចាប់ពីគល់ស្ពានជ្រោយចង្វារតាមបណ្តោយផ្លូវជាតិលេខ៦អា។ ហើយគម្រោងនេះបានបើកការដ្ឋានសាងសង់កាលពីអំឡុងឆ្នាំ២០១២ និងមានទុនវិនិយោគជាង ២ពាន់លានដុល្លារដែលនឹងក្លាយជាទីក្រុងរណបមួយដែលពោរពេញទៅដោយសក្តានុពលខ្លាំងនាពេលខាងមុខហើយបច្ចុប្បន្ននេះតំបន់ជ្រោយចង្វារនេះកំពុងតែទាក់ទាញសំណង់អគារជាច្រើនដូចជា សាលាគយ អគារសាកលវិទ្យាល័យវិចិត្រសិល្បៈ និងបានរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធតាមដងផ្លូវទាំងភ្លើងបំភ្លឺផ្លូវបំពាក់ទៅលើសំណង់អាគារជាដើម។

### ២.១.១. អំពីក្រុមហ៊ុន អូស៊ីអាយស៊ី

ក្រុមហ៊ុន អូស៊ីអាយស៊ី នេះបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ដោយអ្នកឧកញ៉ា ពុង ឃាវសែ អគ្គនាយក និងជាប្រធានក្រុមហ៊ុនវិនិយោគក្រៅប្រទេស។ ហើយម្យ៉ាងវិញទៀតក្រុមហ៊ុន អូស៊ីអាយស៊ី គឺជាក្រុមហ៊ុនសាជីវកម្ម ដែលមានសណ្ឋានក្រោមការគ្រប់គ្រង់របស់ក្រុមហ៊ុនកាណាឌីយ៉ា អ៊ីនធើគ្រែន អ៊ិនធើប្រាយ គ្រុប (Canadia Integrated Enterprise Group) ហើយក៏ជាក្រុមហ៊ុនពហុវិនិយោគដែលឈានមុខគេមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការមានវត្តមានដ៏លេចធ្លោ និងមានសារៈសំខាន់ក្នុងការចូលរួមចំណែកគំនិតផ្តួចផ្តើមវិនិយោគក្នុងការអភិវឌ្ឍសង្គមកម្ពុជាដែលមានសភាពល្អ និងមានភាពចម្រុងចម្រើនដោយបង្កើតបាននូវឱកាសការងាររាប់ពាន់កន្លែង និងទាក់ទាញវិនិយោគិនដែលមានសក្តានុពលខ្លាំង មកកាន់ប្រទេសកម្ពុជាយើងក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ហើយជំនាញចម្បងរបស់ក្រុមហ៊ុន គឺនៅលើការអភិវឌ្ឍសំណង់ និងអចលនទ្រព្យ និងការគ្រប់គ្រងអចលនទ្រព្យជាដើម។ ទន្ទឹម និងនេះក្រុមហ៊ុនក៏មានបទពិសោធន៍នៅក្នុងការសាងសង់អគារពាណិជ្ជកម្មប្រើប្រាស់ចម្រុះ ខុនដូ តំបន់លំនៅដ្ឋាន អាផាតមិន ផ្ទះល្វែង ទីក្រុងរណប ផ្សារទំនើប និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផងដែរ។ គម្រោងអចលនទ្រព្យ និងសំណង់ដែលមានតម្លៃរាប់ពាន់លានដុល្លារដែលដូចជាទីក្រុងរណបជ្រោយចង្វារទីក្រុងកោះពេជ្រ ទីក្រុងអូឡាំព្យា ភូមិវប្បធម៌(ខេត្តសៀមរាប) វិមានកុលាប អាគារកាណាឌីយ៉ា សួនកាណាឌីយ៉ា បុរីឧស្សានបាសាក់ ផ្សារទំនើបអូឡាំព្យា សុរិយា ហើយរួមទាំង សេនធ័រភ័នធ៍ រតនាផ្លាហ្សា និងគម្រោងធំៗជាច្រើនផ្សេងៗទៀតដែលបានបង្កើតឡើងដោយក្រុមហ៊ុន អូស៊ីអាយស៊ី និងដៃគូសហការផ្សេងទៀតផងដែរ។

ទាំងអស់នេះហើយ គឺបានបង្ហាញនូវអំពីកេរ្តិ៍ដំណែលដ៏អស្ចារ្យមួយដែលមានការចូលរួមចំណែកដ៏ធំសន្ធឹកសន្ធាប់ដែលយើងបង្ហាញថាជាក្រុមហ៊ុនវិនិយោគដ៏ល្អបំផុតនៅក្នុងប្រទេសមួយនេះ។ ក្រៅពីគម្រោង

ឯកជនដែលមានប្រាក់ចំណេញ អូស៊ីអាយស៊ី ក៏បានប្រើប្រាស់នូវធនធានរបស់ខ្លួននៅក្នុងការវិនិយោគ និងសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ប្រើប្រាស់សាធារណៈដែលរួមចំណែកធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់មានភាពល្អប្រសើរឡើងផងដែរ។ អូស៊ីអាយស៊ី មានមហិច្ឆតា និងតាំងចិត្តបន្តវត្តមានដ៏មុតមាំនៅក្នុងប្រទេសកម្ពុជា និងកាន់តែជំរុញការវិនិយោគរបស់ក្រុមហ៊ុនឱ្យកាន់តែរីកចម្រើនដើម្បីបន្តការកសាងប្រទេសកម្ពុជាតទៅមុខទៀត។ **ឧទាហរណ៍** ស្ពានអាកាសដែលមានស្រាប់ដោយមានដូចជា ស្ពានអាកាសមុនីវង្ស ស្ពានអាកាស៥មករា ស្ពានអាកាស៧មករា និងស្ពានអាកាសស្ទឹងមានជ័យជាដើម។

ជាពិសេស ទៀតរាល់ការវិនិយោគយ៉ាងសកម្មនៅក្នុងហេដ្ឋារចនាសម្ព័ន្ធសាធារណៈត្រូវបានជម្រុញស្របទៅតាមផែនការនៃចក្ខុវិស័យរបស់រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា នៅក្នុងការកែប្រែទីក្រុងភ្នំពេញឱ្យក្លាយទៅជារាជធានីសតវត្សរ៍ទី២១។ អស់រយៈពេលជាង ១០ឆ្នាំមកហើយកិច្ចការងារដែលបានសម្រេច និងកំពុងបន្តដំណើរការ គឺមិនផ្តោតទៅលើប្រាក់ចំណេញផ្ទាល់ខ្លួននោះទេ ប៉ុន្តែត្រូវបានជំរុញដោយចូលរួមក្នុងការជួយដល់កំណើនសេដ្ឋកិច្ចដែលមានភាពរីដ្ឋមានដើម្បីសម្រេចបាននូវការប្រកួតប្រជែងជាមួយបណ្តាប្រទេសនៅក្នុងតំបន់ដូចជា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងវៀតណាមជាដើមដែលជាគំរូសម្រាប់ប្រទេសកម្ពុជា។ រហូតមកដល់ពេលនេះវត្តមានបន្ត និងភាពជោគជ័យរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី មិនអាចធ្វើទៅបានដោយគ្មានកត្តាប្រាថ្នាចំនួន ០៤ យ៉ាងនោះទេ។

❖ បំណងប្រាថ្នាទាំង ០៤យ៉ាងនោះគឺ៖

- ស្ថិរភាពនយោបាយ និងសន្តិភាពក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាល
- កំណើនសេដ្ឋកិច្ចស្ថិរភាពក្នុងអត្រា៧%ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះដែលអនុញ្ញាតឱ្យកម្ពុជាក្លាយខ្លួនទៅជាប្រទេសចំណូលទាបទៅមធ្យម។
- ការទុកចិត្ត ការគាំទ្រ និងទំនុកចិត្តពីអតិថិជនដៃគូអាជីវកម្ម និងវិនិយោគិនបានជំរុញឱ្យក្រុមហ៊ុន អូស៊ីអាយស៊ី ធ្វើការដោយមិននឿយហត់។
- ការកាន់កាប់នូវធនធានមនុស្ស និងបុគ្គលិកដ៏រឹងមាំដែលមានសមត្ថភាព និងមហិច្ឆតាគួបផ្សំ និងសមត្ថភាពក្នុងការដឹកនាំការងារ ខិតខំប្រឹងប្រែង និងសហការជាមួយគ្នាយ៉ាងទូលំទូលាយដើម្បីជំរុញក្រុមហ៊ុន អូស៊ីអាយស៊ី ទៅមុខដោយមានកិត្តិយស។ អូស៊ីអាយស៊ី ក្នុងនាមជាក្រុមហ៊ុនឈានមុខគេនឹងដាក់ការងារយ៉ាងរឹងមាំជាមួយនឹងចក្ខុវិស័យដ៏រឹងមាំដោយប្រកបទៅដោយគុណភាព និងភាពជាដៃគូក្នុងរយៈពេលវែងដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមរយៈការវិនិយោគលើវិស័យ សំណង់ និង អចលនទ្រព្យ។[៣៥]

[៣៥] គេហទំព័រ http://Www.ocic.kh.com ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

### ២.១.២. សកម្មភាពរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី

អូស៊ីអាយស៊ី គឺជាក្រុមហ៊ុនវិនិយោគឈានមុខគេនៅកម្ពុជា និងជាជម្រើសដៃគូជំនួញសាកលលោកសម្រាប់ក្រុមហ៊ុនស្វែងរកការបណ្ដាក់ទុនក្នុងស្រុក។ នេះជាក្រុមហ៊ុនដែលមានចក្ខុវិស័យរឹងមាំទៅលើវិស័យដែលខ្លួនកំពុងធ្វើប្រតិបត្តិការ និងមានភាពជាសហគ្រិនមានគោលការណ៍ច្បាស់លាស់មានគុណតម្លៃជាអ្នកបង្កើត និងផ្លាស់ប្តូរទៅរកភាពវិជ្ជមានដើម្បីបម្រើដល់ផលប្រយោជន៍ប្រជាជនកម្ពុជា ឧស្សាហកម្ម និងធនធានក្នុងតំបន់ជាច្រើនដែលខ្លួនមានប្រតិបត្តិការ។ ក្រុមហ៊ុន អូស៊ីអាយស៊ី គឺជាក្រុមហ៊ុនដែលផ្តល់លទ្ធភាពជូនទៅដល់ប្រជាជនកម្ពុជាបង្កើតឱកាសឱ្យពួកគេបានសិក្សាស្វែងយល់ និងរីកចម្រើនហើយព្រមទាំងប្រើជំនាញនិងបទពិសោធន៍ទេពកោសល្យរបស់ពួកគេបម្រើដល់អ្នកដទៃ។ ហើយក្រុមហ៊ុន អូស៊ីអាយស៊ី គឺជាក្រុមហ៊ុនមួយដែលរួមបញ្ចូលចំណេះដឹងក្នុងស្រុកជាមួយការប្តេជ្ញាឆ្ពោះទៅកាន់ស្តង់ដារសាកលលោក។

ក្រុមហ៊ុនអូស៊ីអាយស៊ីនឹងបន្តនៅភាពច្នៃប្រឌិត តាមរយៈការស្វះស្វែងរកវិធីចុងក្រោយ និងច្នៃបង្កើតខ្ពស់បំផុតធ្វើដៃគូជាមួយជំនួញក្នុង និងក្រៅប្រទេសអ្នកសហគ្រិនសហប្រតិបត្តិការ និងរដ្ឋាភិបាលក្នុងការបង្កើតជំនួញមានឈ្មោះក្នុងទីផ្សារឈានមុខ។ អូស៊ីអាយស៊ី ខិតខំស្វះស្វែងដោះស្រាយរាល់ការប្រឹងប្រែងជាឱកាសមួយដើម្បីពង្រឹងទំនាក់ទំនងយូរអង្វែងរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី ជាមួយដៃគូនិងវិនិយោគិនផ្សេងៗទៀត។ ម្យ៉ាងវិញទៀតនោះទទួលស្គាល់ថាភាពជោគជ័យរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី នេះ គឺជាវង្វាស់នៃការជឿទុកចិត្តដែលដៃគូវិនិយោគដែលបានធ្វើការសហការមកលើក្រុមហ៊ុន អូស៊ីអាយស៊ី។ ហើយបេសកកម្មរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី គឺជួយដល់ដៃគូ និងវិនិយោគិនអោយសំរេចនូវគោលដៅអាជីវកម្មរបស់ខ្លួនបន្តស្វែងរកការអភិវឌ្ឍវិនិយោគ និងចាប់ដៃគូជាមួយគ្នា និងគាំពារអាជីវកម្មឈានមុខគេនៅលើពិភពលោកតាមរយៈការលាយបញ្ចូលគ្នារវាងមូលធនបញ្ញាហិរញ្ញវត្ថុរួមបញ្ចូលគ្នាជាមួយ ឧត្តមភាព វិជ្ជាជីវៈ និងស្តង់ដារខ្ពស់បំផុតនៃភាពស្មោះត្រង់។ ហើយភាពជាដៃគូមួយក្នុងពេលតែមួយការវិនិយោគម្តងមួយ និងទំនាក់ទំនងមួយក្នុងពេលតែមួយ។[៣៦]

### ២.២. ការរៀបចំតំបន់ អូស៊ីអាយស៊ី នៃខណ្ឌជ្រោយចង្វារប្រកបទៅដោយស្តង់ដារ

បើយោងទៅតាមសៀវភៅរបស់លោកគ្រូសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា បានសរសេរថាក្នុងការ រៀបចំក្រុងជាលក្ខណៈពិធីការមួយត្រូវបានឈរក្រោមគោលការណ៍សសរស្តម្ភចំនួន ០៥ គឺផលិតភាព និរន្តភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ និងរចនាដ៏ល្អប្រសើរជារួមមានន័យថាត្រូវធ្វើយ៉ាងណាបង្កើត កន្លែងមួយដែលមាន ផលិតភាព និរន្តភាព និងភាពដែលអាចរស់នៅបានតាមរយៈភាពជាអ្នកដឹកនាំ និងការរួមបញ្ចូលគ្នានៃរចនាបទទីក្រុងមួយដ៏ល្អប្រសើរ។ ចំពោះការរៀបចំតំបន់ជ្រោយចង្វារឱ្យក្លាយទៅជាតំបន់ប្រកបទៅដោយ

[៣៦] គេហទំព័រ http://Www.ocic.kh.com ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

ស្តង់ដារ គឺជាទីក្រុងមួយមានលក្ខណៈគ្រប់គ្រាន់នូវប្រព័ន្ធផ្សេងៗដែលអំណោយផលសម្រាប់ការរស់នៅរបស់ប្រជាជនបានន័យថាមិនថាទាំងហេដ្ឋារចនាសម្ព័ន្ធ សំណង់ សោភ័ណភាព បរិស្ថាន សន្តិសុខ រួមផ្សំជាមួយ និងសណ្តាប់ធ្នាប់ គឺមានស្តង់ដារ និងមានរបៀបរៀបរយឱ្យស្របទៅតាមគោលនយោបាយនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះផងដែរ ការរៀបចំទីក្រុងមួយដែលប្រកបទៅដោយស្តង់ដារ គឺជាទីក្រុងមានសកម្មភាពដែលស្របជាមួយការយកចិត្តទុកដាក់ខ្ពស់នៅក្នុងការរៀបចំ និងថែរក្សាគុណភាពបរិស្ថានជាមួយនឹងការអភិវឌ្ឍ។[៣៧]

### ២.២.១. តំបន់ដែលមានសណ្តាប់ធ្នាប់

ជាគោលការណ៍តំបន់មួយដែលមានសណ្តាប់ធ្នាប់ត្រូវឈរលើគោលការណ៍ ៣គឺ៖

- សន្តិសុខ
- ភាពស្ងប់ស្ងៀម
- បរិស្ថាន (អនាម័យ)។[៣៨]

### ២.២.២. សន្តិសុខ

នៅក្នុងសន្តិសុខត្រូវបានកំណត់នៅក្នុងគោលការណ៍សំខាន់ៗ ៣គឺ សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។[៣៩]

- **សុវត្ថិភាពបុគ្គល**

សុវត្ថិភាពបុគ្គល គឺសម្តៅដល់សុវត្ថិភាពរបស់បុគ្គលគ្រប់ៗរូប និងមានសេរីដែលគ្មានការបំពានពីសំណាក់បុគ្គលណាម្នាក់ ដែលនាំបង្កឱ្យមានបញ្ហា ពោលគឺមានសុវត្ថិភាព និងការការពារជូនដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះផងដែរ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពក៏បានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គលហើយគោលនយោបាយនេះលក្ខណៈសម្បត្តិ ៩យ៉ាងរួមមាន៖

១. គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មាននូវការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ៗប្រភេទ គ្មាននវូការប្រើប្រាស់អាវុធខុសច្បាប់ និងគ្មាននូវ

---

[៣៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១៣

[៣៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[៣៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

បទល្មើសគ្រប់ប្រភេទ

៦. គ្មានគ្រោះថ្នាក់ចរាចរណ៍

៧. គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨. មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតប ចំពោះគ្រោះមហន្តរាយ ប្រកបដោយ ប្រសិទ្ធិភាព

៩. គ្មានការត្រួតពិនិត្យខុសច្បាប់។[៤០]

បន្ថែមជាមួយគ្នានេះផងដែរ បើយោងទៅតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃក៏បានបន្ថែមផងដែរថាតាមលទ្ធផល ប្រឡងប្រណាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពប្រចាំឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃបានបង្ហាញឱ្យឃើញថាក្នុងចំណោម ឃុំ សង្កាត់ទាំង១២៧ របស់រដ្ឋបាលខេត្តកណ្ដាល ទទួលបានចំណាត់ប្រភេទ១ បានចំនួន ៥០/៥៧ឃុំ ប្រភេទ២ទទួលបាន ៦៩/៦១ ឃុំ-សង្កាត់ ចំណាត់ថ្នាក់ប្រភេទ៣ គឺទទួលបាន ៨/៩ឃុំ និងគ្មានចំណាត់ថ្នាក់ មានចំនួន ០/០ឃុំ។ ទោះបីជាទទួលបានលទ្ធផលគួរជាទីមោទនៈក៏ពិតមែន ប៉ុន្តែការប្រព្រឹត្តទៅនៃចលនាអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព នៅមានបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធដល់ការងារពង្រឹងតួនាទីដឹកនាំការផ្សព្វផ្សាយគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ការកសាងនូវកំលាំងប្រជាការពារ និងការរៀបចំវេទិការសាធារណៈពិសេសការបំផុសចលនាប្រឡងប្រណាំងនៅមិនទាន់ស៊ីជម្រៅ មានលក្ខណៈស្មុគស្មាញ និងបន្ទុកការងារកាន់តែច្រើន។ ទន្ទឹមជាមួយគ្នានេះគណៈបញ្ជាការឯកភាពក្រុង-ស្រុក កងកម្លាំងមានសមត្ថកិច្ច ព្រមទាំងមាននូវ អាជ្ញាធរពាក់ព័ន្ធត្រូវបន្តប្រកាន់ខ្ជាប់នូវទស្សនៈ ភូមិ-ឃុំមានសុវត្ថិភាព ជាភារកិច្ចសំខាន់សម្រាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ត្រូវបង្កើននូវការប្រមូលផ្តុំដឹកនាំនៅក្នុងមូលដ្ឋានឱ្យចូលរួមសកម្មភាព ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈតាមរយៈការកសាងផែនការប្រើប្រាស់កម្លាំងសរុបវិធានការសរុប និងមធ្យោបាយសរុប ព្រមទាំង មានកម្មវិធីប្រជុំបូកសរុបដកពិសោធន៍តាមដំណាក់កាលនីមួយៗសំដៅកែលម្អបង្កើនប្រសិទ្ធភាពថែមទៀតសម្រាប់រដ្ឋបាលក្រុង-ស្រុករបស់ខ្លួន។ បង្កើនការរៀបចំនូវវេទិកាសាធារណៈឱ្យកាន់តែសកម្មបន្ថែមទៀតនោះ ដោយយកចិត្តទុកដាក់ខ្ពស់អំពីគុណភាពនៃការទទួលបានព័ត៌មានអំពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងបញ្ហាសន្តិសុខហើយ និងព្រមទាំងបានខិតខំដោះស្រាយនូវរាល់គ្រប់សំណូមពរទាំងអស់ដែលប្រជាពលរដ្ឋ ក្នុងតំបន់នោះបានលើកឡើងឱ្យរួសរាន់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ គឺសំដៅទៅដល់ការធ្វើឱ្យវេទិកាសាធារណៈមួយឱ្យទទួលបាននូវគុណប្រយោជន៍ពិតៗ និងជាក់ស្តែងហើយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងខេត្ត ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យការអនុវត្តគោលនយោបាយ ភូមិ-ឃុំមាសុវត្ថិភាព ទទួលបាននូវលទ្ធផលល្អធានា

---

[៤០] ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព, លេខ ០២០ ជ.ក, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ការពារសន្តិសុខ និងសណ្ដាប់ធ្នាប់ជូនដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែងដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ។[៤១]

❖ **សុវត្ថិភាពសម្ភារៈ**

សុវត្ថិភាពសម្ភារៈនៅពេលនេះ គឺចង់បានន័យថាមិនត្រឹមតែមិនមានការឆក់ប្លន់នោះទេពោល គឺមានសុវត្ថិភាពដល់សម្ភារៈដែលបម្រើដល់ការរស់នៅរបស់ប្រជាជនរួមមានដូចជា មិនមាននូវការគាស់ផ្ទះ មានការផ្លោះរបង ឬការគាស់ទូរធនាគារ ក្មេងពាល ល្បែងស៊ីសង ឬសកម្មភាពផ្សេងទៀតដែលបង្កឱ្យមានភាពអសន្តិសុខដែលធ្វើឱ្យមានភាពភ័យខ្លាច ដល់ការរស់នៅរបស់ប្រជាជននៅតាមតំបន់ផងដែរ។

ទន្ទឹម ជាមួយគ្នានេះផងដែរក៏ត្រូវមានសន្តិសុខសុវត្ថិភាពដោយមានការយាមពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធបន្ថែមសម្រាប់ភាពកក់ក្ដៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ជាមួយ និងការការពារដោយការយកចិត្តទុកដាក់ខ្ពស់ ជាមួយនឹងបញ្ហាសន្តិសុខ។ ការគិតគូរបែបនេះមិនត្រឹមតែធ្វើឱ្យប្រជាជនមានទំនុកចិត្តនោះទេ គឺថែមទាំងធ្វើឱ្យជនជាតិបរទេស ជាពិសេសជាមួយផ្នែក ទេសចរណ៍ ដែលធ្វើឱ្យមានទំនុកចិត្តជាមួយដំណើរកំសាន្ត។ លើសពីនេះទៅទៀត កាលណាពួកគាត់មាននូវសុវត្ថិភាពពេលចូលមកដល់ប្រទេសកម្ពុជានោះធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងសម្រាប់ការងាររកស៊ីបណ្ដាក់ទុនព្រោះជា ប្រទេសដែលមានសុវត្ថិភាព ដូច្នេះការរកស៊ីក៏មាននូវសុវត្ថិភាព។ ស្ថិតក្នុងបរិបទបែបនេះការវិនិយោគកាន់តែកើនឡើងដែលជាហេតុបណ្ដាលឱ្យសេដ្ឋកិច្ចជាតិកាន់តែមាននូវការអភិវឌ្ឍ និងជួយបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋផងដែរតាមរយៈទេសចរណ៍ក៏ដូចជាការនិយោគផងដែរ។

❖ **សុវត្ថិភាពចំណីអាហារ**

ក្នុងបច្ចុប្បន្ននេះទាំងអាជ្ញាធរ រដ្ឋាភិបាលក៏ដូចជាមន្ត្រីពាក់ព័ន្ធផ្សេងៗបានខិតខំព្យាយាម និងទប់ស្កាត់ផាកពិន័យ រាល់ការនាំចូលនូវរបស់របរ បន្លែ និងចំណីអាហារដែលមិនមានគុណភាពនៅតាមព្រំដែនក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយតម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋមានច្រើន។ ដូចនេះដើម្បីបំពេញតម្រូវឱ្យគ្រប់នូវការប្រើប្រាស់នេះត្រូវទាមទារឱ្យមានចូលរួមពីប្រជាពលរដ្ឋក្នុងការដាំដំណាំ បន្លែ ផ្លែឈើ គ្មានសារជាតិគីមីដោយខ្លួនឯង ទុកប្រើប្រាស់ផង និងដាក់លក់នៅលើទីផ្សារផង ដើម្បីផ្ដល់សុវត្ថិភាពដល់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិផងដែរ។ អ្នកផលិតម្ហូបអាហារ បន្លែ ត្រូវមានគុណធម៌ សច្ចធម៌ មានបច្ចេកទេសខ្ពស់ ដើម្បីជួយបម្រើដល់សុខភាព របស់អ្នកប្រើប្រាស់ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឱ្យប៉ះពាល់ ដល់សុខភាពរបស់អ្នកដទៃតាមរយៈការលក់របស់ដែលមិនមានគុណភាពទៅឱ្យអតិថិជន។ ចំពោះអ្នកប្រើប្រាស់ក៏គួរគប្បីស្វែងយល់ឱ្យបានច្រើននូវរាល់ ផលិតផលណាដែលគួរប្រើប្រាស់ និងមិនគួរប្រើប្រាស់ដូចគ្នាផងដែរ។ ម្យ៉ាងទៀតសម្រាប់អ្នក

[៤១] គេហទំព័រ ក្រសួងមហាផ្ទៃ https://www.interior.gov.kh/report/detail/2325 ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

ដែលប្រើប្រាស់ទាំងអស់ដើម្បីទទួលបានសុវត្ថិភាពចំណីអាហារ បើអាចពិនិត្យលើគុណភាព ចំណីអាហារ យើងគួរគប្បីមុននឹងទិញផលិតផលយកទៅប្រើប្រាស់ហើយយ៉ាងហោចណាស់ក៏បានពិនិត្យមើលទៅ លើកាលបរិច្ឆេទផុតកំណត់ឱ្យបានមួយចំណុចមុនសិនដែរ ដើម្បីធានាឱ្យដឹងថាផលិតផលនោះវានៅអាចប្រើប្រាស់បានហើយបើកន្លែងបរិច្ឆេទផុតកំណត់មានការកោស ឬលុបមានមិនជាន់គ្នានោះ គឺយើងមិនត្រូវទិញផលិតផលនោះយកទៅប្រើប្រាស់នោះឡើយ។[៤២] ជារួមអាហារដែលមានសុវត្ថិភាព គឺយើងត្រូវពិនិត្យទៅលើបញ្ហាមួយចំនួនដែលជាកត្តាចាំបាច់មានដូចជា កាលបរិច្ឆេទនៃការផុតកំណត់ អនាម័យ ការវេចខ្ចប់ ការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ជាពិសេសជាងនេះ ទៅទៀតស្ថាប័នដែលពាក់ព័ន្ធខាងគីមីចំណីរអាហារ គឺត្រូវបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងថែរក្សាសុខភាពរបស់ ប្រជាពលរដ្ឋ និងអនុវត្តយ៉ាងតឹងរឹងតាមរយៈការចុះត្រួតពិនិត្យទំនិញខុសច្បាប់ និងធ្វើការដាក់ទោសជនដែលនាំចូល ឬលក់ផលិតផលចំណីអាហារដែលខូចគុណភាព ដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋដែលលក់ចំណីអាហារក៏ត្រូវចូលរួមចំណែកដូចគ្នាក្នុងការថែរក្សាអនាម័យចំណីអាហារដើម្បីសុខភាពអ្នកបរិភោគ។ ទន្ទឹម និងនេះដែរបើយោងតាមរយៈសេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដែលត្រូវបានហាមឃាត់មាន៦ប្រភេទដូចខាងក្រោម៖

១. ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ

២. គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ

៣. ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់

៤. ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង ទឹកស៊ីរ៉ូប៍គ្រប់ប្រភេទ

៥. ចាហួយ នំផ្អែមខ្លាំងគ្រប់ប្រភេទ

៦. ស្ករគ្រាប់ ស្ករសូកូឡា ស្ករកៅស៊ូ។[៤៣]

### ២.២.៣. ភាពស្ងប់ស្ងៀម

ភាពស្ងប់ស្ងៀម គឺសម្តៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសំឡេង។[៤៤] ស្ថិតក្នុងបរិបទបែបនេះការដែលមិនមានការបំពុលដោយសំឡេង គឺជាការរស់នៅដោយមានភាពស្ងប់ស្ងៀមដោយមិនមានការរំខានដោយសំឡេងផ្សេងដែលអាចបង្កជាការ រំខានទៅដល់ការរស់នៅប្រចាំថ្ងៃដែលចេញមកពីប្រភពផ្សេងៗជាច្រើនដូចជា មិនមានសំឡេងចេញពីការដ្ឋាន រោងចក្រសហគ្រាស រថយន្ត សំឡេងតាមរយៈការបំពងសំឡេង

---

[៤២] គេហទំព័រ http://www.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

[៤៣] សេចក្តីណែនាំស្តីពី ចំណីអាហារនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន, លេខ ១៨ អយក.សណន, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩

[៤៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី២

ឬចេញពីប្រភពណាមួយរួមទាំងការរំខានដោយសំឡេងគ្រប់ប្រភេទ គឺត្រូវបានហាមឃាត់ ឬមានវិធានការយ៉ាងតឹងរឹង ចំពោះបញ្ហាទាំងអស់នេះ។ ម្យ៉ាងវិញទៀតការធ្វើបែបនេះវាបានបង្កឱ្យការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ នោះទទួលបាននៅការរស់នៅដែលប្រកបទៅដោយភាពស្ងប់ស្ងៀមព្រោះមិនមានការរំខានដល់អារម្មណ៍រាល់ការសម្រាករបស់ប្រជាជននៅក្នុងតំបន់នោះពីប្រភពផ្សេងៗ។ បន្ថែមពីនេះទៅទៀតភាពស្ងប់ស្ងៀមគឺពិតជាមាន សារៈសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនគ្រប់រូបដែលនៅក្នុងតំបន់នោះពីព្រោះ ថាកាលណាបើមានការរំខានដោយសំឡេងជាការបំពុលនោះ ការរស់នៅប្រចាំថ្ងៃប្រាកដជាមានការពិបាកនៅក្នុងការរស់នៅពីព្រោះវាបានយាយីដោយការរំខាន ជាខ្លាំងដល់សតិអារម្មណ៍ មិនទទួលបានអារម្មណ៍សម្រាកគ្រប់គ្រាន់។ ដូច្នេះហើយស្ថាប័នដែលពាក់ព័ន្ធត្រូវតែមាននូវវិធានការសម្រាប់ទប់ស្កាត់ក៏ដូចជា មានវិធានការសម្រាប់ដាក់ចេញសម្រាប់ការគ្រប់គ្រងការបំពុលដោយសំឡេង ជូនដល់ប្រជាពលរដ្ឋ ក្នុងគោលបំណងអាចធានាបានថាប្រជាពលរដ្ឋរស់នៅបានដោយភាពស្ងប់ស្ងៀម ដោយគ្មានការបំពុលឬរំខានដោយសំឡេងចំពោះការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ។

### ២.២.៤. ការថែរក្សាបរិស្ថាន

បរិស្ថាន គឺជាមជ្ឈដ្ឋានដែលនៅជុំវិញខ្លួនយើង ឬជារបស់របរវត្ថុដែលនៅឡោមព័ទ្ធយើង ហើយមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់បណ្តាភាវៈ។ បរិស្ថានចែកចេញជា៣ផ្នែកគឺៈ

- **បរិស្ថានធម្មជាតិ** រួមមានបរិស្ថានគ្មានជីវិត (ទឹក ដី ភ្លើង ខ្យល់ ភ្នំ ព្រៃឈើ) និងបរិស្ថានមានជីវិត (មនុស្សសត្វ និងរុក្ខជាតិ)
- **បរិស្ថានមនុស្ស** ជាសំណុំលក្ខខណ្ឌរូបសាស្ត្រ គីមី ជីវសាស្ត្រ រួមជាមួយកត្តាសង្គមនានាដែលកំណត់ការរស់នៅរបស់មនុស្សក្នុងពេលជាក់លាក់ណាមួយ
- **បរិស្ថានសង្គម** មានដូចជាសំណង់អគារ ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រោងចក្រ សហគ្រាស សិប្បកម្ម សួនច្បារ វិមានរដ្ឋសភា វិមានរាជរដ្ឋាភិបាល និងសកម្មភាពសង្គមផ្សេងៗទៀត។[៤៥]

នៅក្នុងបរិបទនេះផងដែរបរិស្ថាន គឺបានសំដៅដល់មជ្ឈដ្ឋានជុំវិញដែលយើងរស់នៅប្រកបទៅដោយភាពសុខដុមបានន័យថាបរិស្ថានដែលនៅជុំវិញខ្លួនយើងមានភាពល្អប្រសើរសម្រាប់ការរស់នៅដូចជា ឬទីធ្លាទីតាំងនៃតំបន់កន្លែងលំហែកាយ អនាម័យ ព្រមទាំងទំនើបកម្មនៃការរស់នៅជាច្រើនដែលអាចបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ទីក្រុងរណបជ្រោយចង្វារកាន់តែទទួលបាននូវភាពល្អប្រសើរ។ ទន្ទឹមជាមួយគ្នានេះផងដែរបរិស្ថាននៅតំបន់នេះ គឺត្រូវតែមានការរៀបចំជាលក្ខណៈស្តង់ដារ ដែលអាចបម្រើដល់ការរស់នៅរបស់ប្រជាពលរដ្ឋទទួលបាននូវភាពដ៏ល្អប្រសើរ និងទំនើបកម្មស្របតាមសម័យកាលទំនើបនៃការរស់នៅ

[៤៥] គេហទំព័រ https://www.khsearch.com/qna/16521 ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

របស់ប្រជាជនក្នុងតំបន់ឱ្យទទួលបាននូវគុណភាពពិតប្រាកដ នៃការរស់នៅជាមួយនឹងបរិស្ថានល្អដែលប្រកប ទៅដោយ ការរៀបចំនៃបច្ចុប្បន្នភាព។ ដោយសារតែបរិស្ថានមានសារៈសំខាន់ខ្លាំងសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ហើយក៏មាននូវការទទួលរងនូវផលប៉ះពាល់ពីសកម្មភាពមួយចំនួនរបស់មនុស្សផងដែរ។ ទើបមានការបង្កើត ច្បាប់បរិស្ថានមានដែលមាននូវគោលបំណង គឺផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ក្នុងការវាយតម្លៃពី ប៉ះពាល់បរិស្ថានការគ្រប់គ្រងធម្មជាតិ កិច្ចការពារ បរិស្ថាន កាត្រួតពិនិត្យ កំណត់ហេតុ និងអធិការកិច្ចការចូលរួម របស់សាធារណជន និងការស្រង់ព័ត៌មានមូល និធិទាយជូទានបរិស្ថាន ទោសបញ្ញត្តិ និងអនុសាន្តបញ្ញត្តិនៃ ច្បាប់នេះ។ អនុសញ្ញាអន្តរជាតិឆ្នាំ១៩៩៨ ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិ ស្តីពីវិស័យបរិស្ថានមានដូចខាងក្រោម៖

- អនុសញ្ញាស្តីពី តំបន់ដីសើមអន្តរជាតិនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦
- អនុសញ្ញាស្តីពី ជីវៈចំរុះនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៥
- អនុសញ្ញាស្តីពី ការប្រែប្រួលអាកាសធាតុនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៥
- អនុសញ្ញាស្តីពី ការបំពុលសមុទ្រដោយនាវានៅខែវិច្ឆកា ឆ្នាំ១៩៩៤
- អនុសញ្ញាស្តីពី ច្បាប់សមុទ្ររបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៦
- អនុសញ្ញាវីយ៉េន និងពិធីសាម៉ុងរ៉េអាល់ស្តីពីធាតុបំពុលស្រទាប់អូសូនថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១
- អនុសញ្ញាស្តីពី ការធ្វើពាណិជ្ជកម្មអន្តរជាតិសត្វព្រៃនិងរុក្ខជាតិថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៧
- អនុសញ្ញាស្តុកខូមស្តីពី សារធាតុពុលសរីរាង្គមិនបំបែកធាតុនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១
- អនុសញ្ញាស្តីពីការប្រឆាំងនឹងរហោរស្ថានកម្មនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣
- អនុសញ្ញាបេតិកភណ្ឌធម្មជាតិពិភពលោកមានដូចជា៖ ដែនជំរកសត្វព្រៃ ភ្នំសំកុល ឪរ៉ាល់ ភ្នំគូលែន ព្រហ្មទេព ឋបនីយជីវមណ្ឌលបឹងទន្លេសាបនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១។

ទន្ទឹមនឹងនេះមានលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលបានចូលរួមដើម្បីការគាំទ្រការថែរក្សាបរិស្ថាន យ៉ាងតឹងរឹង។ ជាមួយគ្នានេះផងដែរក៏មានស្ថាប័នជាច្រើនដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការចូលរួម ថែរក្សាបរិស្ថានផងដែរ។

**២.២.៥. ប្លង់គោល**

ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារដែលស្របទៅតាមប្លង់គោលរបស់រាជធានីភ្នំពេញ គឺជាការអភិវឌ្ឍ ប្រកបដោយភាពត្រឹមត្រូវ លើសពីនេះអាចទាក់ទាញអ្នកវិនិយគឱ្យចាប់អារម្មណ៍ជាមួយគម្រោងនេះជាពិសេស អាចចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបែងចែកតំបន់នៅក្នុងការរស់នៅ ក៏ដូចជាការប្រកបអាជីវកម្ម របស់ប្រជាពលរដ្ឋយ៉ាងល្អប្រសើរ។ ផ្ទុយវិញប្រសិនបើគម្រោងនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារដែលមិន

ស្របទៅតាមប្លង់គោល វាអាចនឹងបង្កើតជាបញ្ហានៅពេលអនាគតជាពិសេសធ្វើឱ្យគម្រោងអភិវឌ្ឍន៍ទាំងមូលជួបភាពខាតបង់ទៀតផង។ ដើម្បីបញ្ចៀសរាល់បញ្ហាប្រឈមនៅថ្ងៃអនាគត រដ្ឋាភិបាលនិងស្ថាប័នដែលពាក់ព័ន្ធនានាត្រូវតែមាននូវផែនការឱ្យបានច្បាស់លាស់ ទាំងការអភិវឌ្ឍនៅពេលបច្ចុប្បន្ន ក៏ដូចជាបន្តទៅថ្ងៃអនាគតក្នុងរយៈពេលវែងដែលក្រៅពីគិតទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ត្រូវគិតទៅលើការបង្កើត និងថែរក្សាតំបន់បៃតងឱ្យបានកាន់តែច្រើន ដែលជាចំណែកមួយយ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ កត្តាដែលនាំឱ្យមានការរៀបចំប្លង់គោលរាជធានីភ្នំពេញជាពិសេសប្លង់គោលទីក្រុងរណបជ្រោយចង្វារ គឺដើម្បីបង្កបានជាលក្ខណៈភាពងាយស្រួលនៅក្នុងការអភិវឌ្ឍសម្រាប់តំបន់ទីក្រុងរណបជ្រោយចង្វារដែលប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ ដែលស្របទៅនឹងបរិបទនៃការរស់នៅដូចជា តំបន់លំនៅឋាន តំបន់សេដ្ឋកិច្ច ក៏ដូចជាតំបន់សេដ្ឋកិច្ចឧស្សាហកម្មជាដើម។[៤៦]

## ២.៣. ការរៀបចំសោភ័ណភាពនៃតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី

នៅក្នុងពេលបច្ចុប្បន្ននេះ តំបន់ជ្រោយចង្វារ ជាពិសេសតំបន់កំពុងអភិវឌ្ឍន៍របស់អូស៊ីអាយស៊ីបានកំពុងតែអភិវឌ្ឍន៍លូតលាស់ទៅមុខឥតឈប់ ដែលបានប្រែក្លាយតំបន់នេះពី តំបន់ដែលមានតែវាលលំហ ទៅជាតំបន់មួយដែលមានទាំងផ្លូវថ្នល់ អគារខ្ពស់ៗ គម្រោងបុរី និងសួនច្បារយ៉ាងល្អស្រស់ឆើតឆាយស្រស់បំព្រងដ៏គួរឱ្យទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាជននៅក្នុងទីក្រុងភ្នំពេញជាខ្លាំង។

### ២.៣.១. សោភ័ណភាពពេលថ្ងៃ

សោភ័ណភាពពេលថ្ងៃ គឺសម្តៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី ព្រមទាំងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ រាប់បញ្ចូលទាំងថ្មើរជើង ដែលប្រកបទៅដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយថែមទៀតផង។[៤៧]

### ២.៣.២. សោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ គឺសម្តៅដល់លើការបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវ មន្ទីរពេទ្យ សាលារៀន និងអគារនានា និងតាមដងវិថីនានានានៅក្នុងទីក្រុង ជាពិសេស គឺការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌នាពេលរាត្រីនៅតាមសួនច្បារសាធារណៈនានា នៅក្នុងទីក្រុង។[៤៨] ម្យ៉ាងវិញទៀតវា គឺជាការលម្អមួយដែលធ្វើឱ្យទីក្រុងកាន់តែមានសោភ័ណ ជាមួយនឹងការបំភ្លឺបែបនេះ។ ចំណែកការធ្វើដំណើរទៀតសោតជាពិសេស គឺតំបន់ជ្រោយចង្វារផ្ទាល់តែម្តង គឺបានបង្កជាភាពងាយស្រួលដល់ការធ្វើ ដំណើររបស់ប្រជាជនដែលធ្វើដំណើរឆ្លងកាត់ផងដែរ។

---

[៤៦] គេហទំព័រ https://www.propertyarea.asia/ ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

[៤៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[៤៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

## ២.៤. គម្រោងដែលកំពុងអភិវឌ្ឍន៍ក្នុងតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី

បច្ចុប្បន្ននេះគម្រោងដែលអភិវឌ្ឍន៍មួយចំនួននៅក្នុងតំបន់អភិវឌ្ឍន៍ជ្រោយចង្វារនេះ គឺបានសម្រេចការសាងសង់រួចរាល់ជាផ្លូវការមានដូចជា សួនកម្សាន្តដាយណូស័រ ផ្សារសាគូរ៉ា ទីក្រុងរថយន្ត អគារពោងការមណ្ឌលសន្និបាត សកលវិទ្យាល័យខេមតិច និងពិព័រណ៍អន្តរជាតិជ្រោយចង្វារអូស៊ីអាយស៊ីជាដើម។ ហើយដោយឡែកគម្រោងមួយចំនួនដែលកំពុងស្ថិតនៅក្នុងដំណាក់កាលសាងសង់នៅឡើយ។

### ២.៤.១. គម្រោងដែលសម្រេចបាន

តំបន់ជ្រោយចង្វារជាតំបន់ដែលកំពុងអភិវឌ្ឍន៍ ទាំងវិស័យសំណង់និងវិស័យផ្សេងៗទៀតផងដែលហើយគម្រោងដែលសាងសង់រួចមានដូចជា អាគារពិព័រណ៍អន្តរជាតិដែលមានតម្លៃ ១៦លានដុល្លារអាមេរិកដែលបានសាងសង់រួចរាល់នៅខណ្ឌជ្រោយចង្វារ ស្ថិតនៅក្នុងសង្កាត់ព្រែកតាសេក ដែលជាសំណង់អាគារសាធារណៈធំទី២ បន្ទាប់ពីសាលពិព័រណ៍ កោះពេជ្រដែលវិនិយោគដោយក្រុមហ៊ុន អូស៊ីអាយស៊ី អាគារពិព័រណ៍អន្តរជាតិនេះសាងសង់លើផ្ទៃដីសរុប២៦,៧៧៤,៣៨ម៉ែត្រការ៉េ ដោយបានបែងចែកអគារជា ០៣ផ្នែកធំៗរួមមាន៖

- អគារសំរាប់ពិព័រណ៍ឃ្លាំង និងផ្ទះបាយនៅខាងក្រោយអគារពិព័រណ៍ និងចំណតរថយន្តក្រោមដីដែលអាចឱ្យយានយន្តចតបាន១៩៨កន្លែង។ ចំពោះរយៈពេលនៅក្នុងការសាងសង់តួអគារទាំងមូលនេះមានរយៈពេលសរុប១៤ខែ គិតចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

  នេះជាសមិទ្ធផលមួយដែលបានកើតឡើងនៅក្នុងតំបន់ជ្រោយចង្វាររាជធានីភ្នំពេញនៅពេលដែលកំណើនប្រជាពលរដ្ឋនៅក្នុងទីក្រុងក៏កើនឡើង ឯតម្រូវការហោដ្ឋារចនាសម្ពន្ធ័គ្រប់ប្រភេទ ក៏ដូចជាអគារសាធារណៈផ្សេងៗទៀត ក៏មានការកើនឡើងហើយការវិនិយោគទាំងនៅក្នុង និងក្រៅប្រទេស ក៏ដូចជាភ្ញៀវទេសចរក៏មានការកើនឡើងឥតឈប់ឈរនៅក្នុងបរិបទដែលប្រទេសកម្ពុជាមានសុខសន្តិភាព ក៏ដូចជា មានស្ថេរភាពនយោបាយដ៏ពេញលេញ។

- សាលាជាតិគយត្រូវបានបង្កើតជាផ្លូវការតាមរយៈប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនិងនេះចាប់ពីខែតុលា ឆ្នាំ២០១៩ មកដោយមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការដ្ឋានសាងសង់អគារសាលាជាតិគយ គឺត្រូវបានចាប់ផ្ដើមដំណើរការជាផ្លូវការក្រោមការដឹកនាំគ្រប់គ្រងផ្ទាល់របស់ឯកឧត្តមបណ្ឌិត គុណ ញឹម រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ការដ្ឋានសំណង់ដ៏ស៊ីមស្ពែនេះ គឺស្ថិតលើផ្ទៃដីទំហំ១ហិកតាក្នុងតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន អូស៊ីអាយស៊ី នេះបណ្ដាក់ទុនវិនិយោគកម្ពុជា និងក្រៅប្រទេសខណ្ឌជ្រោយចង្វាររាជធានីភ្នំពេញ។ អគារសាលាជាតិគយនេះមានកម្ពស់ ១២ជាន់ ដែលបំពាក់

ទៅដោយសម្ភារបរិក្ខារទំនើប មានសាលប្រជុំតូចធំ បណ្ណាល័យ សាលសិក្សា តារាងបាល់ទាត់ តារាងវាយសី អាហារដ្ឋាន ដែលនឹងចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស។

- ស្ពានបេតុងឫស្សីកែវ ត្រូវបានវិនិយោគសាងសង់នៅពាក់កណ្តាលឆ្នាំ២០២១ដែលមានប្រវែង ៩២២ ម៉ែត្រ ទទឹង២០.៥ម៉ែត្រ។ ស្ពានបេតុងឫស្សីកែវដែលជាស្ពានខ្សែកាបទីមួយ ក្នុងទីក្រុងភ្នំពេញត្រូវបានគេប្រមាណថានឹងក្លាយជាសរសៃឈាម និងច្រកសេដ្ឋកិច្ចដ៏សំខាន់ដើម្បីលើកតម្កើនប្រជាប្រិយភាពនៅក្នុងវិស័យអចលទ្រព្យ ការធ្វើចរាចរឆ្លងកាត់ទៅតំបន់ជ្រោយចង្វារកាន់តែមានភាពងាយស្រួល កាត់បន្ថយគ្រោះថ្នាក់ ការកកស្ទះ និងជាពិសេសធ្វើឱ្យតម្លៃដីធ្លីនៅតំបន់នេះគឺកាន់តែមានតម្លៃខ្ពស់ជាងមុន។ ស្ពាននេះមានចិញ្ចើមស្ពានសម្រាប់ថ្មើរជើងមានទទឹង ១.២៥ម៉ែត្រសងខាងហើយកម្ពស់សរសរស្ពាន គឺសម្រាប់ព្យួរខ្សែកាបធៀបនឹងកម្រាលស្ពានប្រវែង ៣៤ម៉ែត្របន្ថែមដោយរចនាបទទំនើបដែលមានសរសធំចំនួន ០៤បង្គោល និងមានកំពស់រហូតដល់៤០ម៉ែត្រ ចំណាយអស់ទឹកប្រាក់ប្រមាណ ៣៥ លានដុល្លារ អាមេរិក ស្ពាននេះផ្សារភ្ជាប់ខណ្ឌធំៗចំនួនពីរ គឺខណ្ឌឫស្សីកែវផ្លូវជាតិលេខ៥ ដោយបានឆ្លងកាត់តាមរង្វង់មូលសុវណ្ណមច្ឆានៅក្នុងតំបន់ជ្រោយចង្វារ លើមហាវិថី អូស៊ីអាយស៊ី ទៅកាន់ផ្លូវជាតិលេខ៦អា នៃខណ្ឌជ្រោយចង្វារ។

### ២.៤.២. គម្រោងកំពុងអភិវឌ្ឍន៍

នៅក្នុងតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី បើនៅតាមបណ្តោយផ្លូវជាតិលេខ៦អា គឺមានអគារពន្ធដារថ្មីនឹងបង្ហាញរូបរាងយ៉ាងស្កឹមស្កៃនៅតំបន់ជ្រោយចង្វារមានកម្ពស់៣២ជាន់ ដែលនៅក្នុងនោះមានផ្ទៃក្រឡាសាងសង់សរុប ៩៧៧០០ម៉ែត្រក្រឡាលើសពីនេះទៅទៀតក៏នូវមានទីតាំងចំណតរថយន្តប្រមាណជាង ១៣០០ចំណតសម្រាប់មន្ត្រីរាជការកិច្ចប្រជុំធំៗ និងសាធារណៈជនទូទៅ។ ទន្ទឹម និងនេះផងដែរនៅក្នុងគម្រោងសាងសង់អគារពន្ធដារថ្មីនេះ គឺត្រូវបានគូសប្លង់ស្ថាបត្យកម្មផ្ទាល់ដោយក្រុមហ៊ុន អេដាស ប្រទេសសិង្ហបុរី ព្រមទាំងមានក្រុមហ៊ុន (Oliver & Ho Association) ជាទីប្រឹក្សាបច្ចេកទេសគ្រប់គ្រងគម្រោងដោយសហការសាងសង់ដោយក្រុមហ៊ុន (Shanghai Construction)។ ផ្តើមចេញពីដំណាក់កាលការងារគ្រឹះអគារហើយគម្រោងនេះ និងប្រើពេលវេលាសាងសង់ប្រមាណ ២៤ខែ ឬ២ឆ្នាំ ដែលអគារនេះមានតម្លៃ ៦០លានដុល្លាអាមេរិក។ ចំណែកឯអគាររបស់អគ្គនាយកដ្ឋានពន្ធដារថ្មី គឺមានទីតាំងស្ថិតនៅ ភូមិជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលនឹងក្លាយជាទីតាំងបណ្តុំនៃសេវាសាធារណៈជូនអ្នកជាប់ពន្ធនៅក្នុងតាំងតែមួយ ដោយអគារអគ្គនាយកដ្ឋានពន្ធដារក៏មានទីតាំងផ្តល់សេវាជូនទៅដល់អ្នកជាប់ពន្ធប្រកបដោយនូវផាសុកភាព និងប្រណិតភាពផងដែរហើយក៏មាននូវផ្សារទំនើបធនាគារផ្សេងជាដៃគូក្នុងការផ្តល់សេវាទទួល និងបង់ប្រាក់ពន្ធក្រុមហ៊ុនសហគ្រាសនានាដែលផ្តល់សេវាគាំទ្រផ្នែកពន្ធដារ។

### ២.៤.៣. គម្រោងកំពុងស្ថិតក្នុងការសិក្សា

ក្នុងតំបន់ជ្រោយចង្វារកំពុងតែមានភាពទាក់ទាញលើការអភិវឌ្ឍជា តំបន់ពាណិជ្ជកម្មនិងលំនៅឋានដោយឃើញមានអគារពាណិជ្ជកម្មធំៗ និងគម្រោងលំនៅឋានជាច្រើនចាប់ផ្តើមលេចរូបរាងជាបន្តបន្ទាប់។

ក្រុមហ៊ុនផ្សារទំនើបដ៏ធំរបស់ថៃ ប៊ីកស៊ី ក៏បានចុះហត្ថលេខាជាមួយក្រុមហ៊ុន អូស៊ីអាយស៊ី ក្នុងការពង្រីកប្រតិបត្តិការលក់រាយរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ជាមួយនឹងផែនការចំណាយទុនរួមគ្នាលើប្រមាណ ៥០លានដុល្លារអាមេរិក។ យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រុមហ៊ុន អូស៊ីអាយស៊ី ដែលបានចែកចាយដល់បណ្តាញសារព័ត៌មានក្រោយពិធីចុះហត្ថលេខារវាង អូស៊ីអាយស៊ី និងក្រុមហ៊ុនផ្សារទំនើប ប៊ីកស៊ី កាលពីព្រឹកថ្ងៃទី២២ មេសា ២០២៣ បានឱ្យដឹងថាការចុះអនុស្សរណៈរវាងក្រុមហ៊ុនកម្ពុជា និងផ្សារទំនើបរបស់ថៃនឹងបង្កើតនូវភាពអស្ចារ្យមួយសម្រាប់តំបន់ជ្រោយចង្វារដែលជាតំបន់លំនៅឋាន និងពាណិជ្ជកម្មដ៏ធំមួយដែលមានសក្តានុពល។ គម្រោងនេះនឹងអភិវឌ្ឍន៍ជាភោជនីយដ្ឋានទំនើបៗ ទីតាំងលក់ផលិតផលនាំចូលកន្លែងដើរទិញទំនិញដ៏មានបរិយាកាសល្អ និងកន្លែងផ្តល់សេវាកម្មជាច្រើនទៀត។ ម្យ៉ាងវិញទៀតផ្សារទំនើប ប៊ីកស៊ី មានទំហំផ្ទៃដីប្រមាណ ២,៧ហិកតាហើយនឹងត្រូវសាងសង់នៅជាប់នឹងរង្វង់មូលនាងមច្ឆា ដែលជាតំបន់កំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគិន និងមានប្រជាពលរដ្ឋឆ្លងកាត់តំបន់នោះយ៉ាងមមាញឹកផងដែរខណៈស្ពានថ្មីមួយឆ្លងពីជ្រោយចង្វារ ទៅឬស្សីកែវ។[៤៩]

[៤៩] គេហទំព័រ http://Www.ocic.kh.com ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដាររបស់ក្រុមហ៊ុន អូស៊ីអាយស៊ី មានកត្តារួមផ្សំយ៉ាងច្រើនដែលធ្វើឱ្យតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី មានការអភិវឌ្ឍយ៉ាងខ្លាំងដែលលក្ខខណ្ឌមួយចំនួនរួមមានជាច្រើនដូចជា ការរៀបតំបន់ឱ្យមានសណ្តាប់ធ្នាប់ មានសន្តិសុខ សោភ័ណភាព ជាពិសេសមានការបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធជាមួយ និងការសាងសង់នូវសំណង់អាគារតូចធំទំនើបៗ រួមទាំងមានការថែរក្សាបរិស្ថានដោយមិនមានការបំពុលផ្សេងៗនៃបរិស្ថានសង្គមនៃការរស់នៅ ដែលស្របតាមគោលការណ៍នៃការសាងសង់ដូចជា ការរៀបចំនូវផែនការអភិវឌ្ឍទាំងនោះត្រូវគោរពតាម គោលការណ៍របស់ច្បាប់ស្តីពីបរិស្ថាន ក៏ដូចជាច្បាប់ស្តីពីសំណង់ និងប្លង់គោលរួមជាមួយ និងបច្ចេកទេស ដើម្បីឱ្យការរៀបចំក្នុងតំបន់ជ្រោយចង្វារទៅតាមស្តង់ដាររបស់ក្រុមហ៊ុន អូស៊ីអាយស៊ី។ ជាមួយគ្នានេះផងដែរ សាលាខណ្ឌជ្រោយចង្វារ ជាពិសេសអគ្គនាយករបស់ក្រុមហ៊ុន អូស៊ីអាយស៊ី បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដារ អូស៊ីអាយស៊ី ដែលផ្តោតសំខាន់ទៅលើការរៀបចំក៏ដូចជា ការអភិវឌ្ឍតំបន់នេះប្រកបដោយទំនើបកម្មសំណង់អាគារ ជាមួយនឹងសន្តិសុខនៃការអភិវឌ្ឍ ដោយអមជាមួយនឹងការថែរក្សានូវបរិស្ថានឱ្យបានល្អប្រសើរ រួមទាំងការដែលមិនធ្វើឱ្យមានផលប៉ះពាល់ដល់បរិស្ថាននៃសំណង់នៅក្នុងតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី។ លើសពីនេះទៅទៀតកត្តាដែលជំរុញឱ្យមានការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដារអូស៊ីអាយស៊ីក៏បានចូលរួមយ៉ាងសំខាន់អំពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធក៏ដូចជា ការវិនិយោគធំៗផ្សេងៗទៀតដែលស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលនឹងច្បាប់ដែលកំណត់អំពីការអភិវឌ្ឍផ្សេងៗ។ ពេលបច្ចុប្បន្នស្ថាប័នដែលពាក់ព័ន្ធជាពិសេសស្ថាប័នដែលគ្រប់គ្រងផ្ទាល់នៅតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី គឺបានខិតខំបំពេញតម្រូវការនៃការវិនិយោគដើម្បីធ្វើយ៉ាងណាឱ្យតំបន់នេះក្លាយជាតំបន់ អូស៊ីអាយស៊ី ដែលមានសក្តានុពលមិនថាវិស័យសំណង់ មិនថាវិស័យហេដ្ឋារចនាសម្ព័ន្ធជាមួយ និងប្រព័ន្ធគ្រប់គ្រងតាមបែបបច្ចេកវិទ្យាទំនើបរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី ព្រមទាំងការកំសាន្ត និងទេសចរណ៍ គួបផ្សំជាមួយនឹងទំនើបកម្មនៃសំណង់ ប្រណីតភាពការរស់នៅ និងការថែរក្សាបរិស្ថាន។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថាការអភិវឌ្ឍតំបន់ជ្រោយចង្វារតាមស្តង់ដារ អូស៊ីអាយស៊ី គឺពិតជាមានសារៈសំខាន់ណាស់ពីព្រោះការអភិវឌ្ឍតំបន់នេះ គឺបានផ្តល់សារៈសំខាន់យ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជាតាមរយៈការវិនិយោគ ក៏ដូចជាសំណង់ទំនើបៗ ដែលអាចបង្កជាលក្ខណៈងាយស្រួលរស់នៅសម្រាប់ប្រជាជនគ្រប់លំដាប់ថ្នាក់ ទៅតាមការបំពេញតម្រូវការយ៉ាងពេញចិត្តជាមួយនឹងការរស់នៅជាមួយនឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការយ៉ាងសម្បូរបែបដែលកើតចេញពីទីក្រុងដែលមានការរៀបចំយ៉ាងល្អលើគ្រប់វិស័យជាមួយនឹងការថែរក្សាបរិស្ថានប្រកបទៅដោយគុណភាព។

# អនុសាសន៍

# អនុសាសន៍

យោងទៅតាមការពិនិត្យមើលតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី ឃើញថា ពិតជាមានការអភិវឌ្ឍក៏ដូចជាការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយក្នុងនោះផងដែរមានការអភិវឌ្ឍ ផ្សេងៗទៀត ជាច្រើនមិនថាវិស័យសំណង់ ឬហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាទំនើបកម្មនៃសំណង់រួមផ្សំជាមួយ នឹងសោភ័ណភាពនៃបរិស្ថានសណ្តាប់ធ្នាប់ និងសំណង់សំខាន់ៗទៀតដែលផ្តល់ភាពងាយស្រួលជូនដល់ ប្រជាពលរដ្ឋនៅតំបន់នោះដែលជាកត្តាបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយទោះបីជាមានការអភិវឌ្ឍខ្លាំងប៉ុន្តែនៅតែមានបញ្ហាបន្តិចបន្តួចដែល អាចបង្កជាបញ្ហាកើតឡើងក៏ដូចជា មានផលលំបាកមួយចំនួនសម្រាប់ការអភិវឌ្ឍប៉ុន្តែទោះជាយ៉ាងនេះក្តី បញ្ហាទាំងអស់នោះ គឺត្រូវបានអគ្គនាយកក្រុមហ៊ុន អូស៊ីអាយស៊ី ក៏ដូចជារដ្ឋបាលខណ្ឌជ្រោយចង្វារក៏ដូចជា ថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលបានយកចិត្តទុកដាក់ គឺធ្វើយ៉ាងណាឱ្យការអភិវឌ្ឍដំណើរការទៅមុខយ៉ាងរលូន ជាមួយនឹងការខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍតំបន់នោះផងដែរ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះនាងខ្ញុំ និងខ្ញុំបាទ សូមសេចក្តីអនុញ្ញាតបញ្ចេញជាមតិសំណូមពរ មួយចំនួនដូចជា៖

- សូមស្នើសុំដល់អាជ្ញាធរដែលពាក់ព័ន្ធនៅតែបន្តយកចិត្តទុកដាក់ទៅលើការវិនិយោគ ជាពិសេស គឺ ក្រុមហ៊ុន អូស៊ីអាយស៊ី ដែលជាក្រុមហ៊ុនវិនិយោគធំមួយដើម្បីធ្វើឱ្យទីក្រុងមានភាពរីកចម្រើន ហើយ ជាពិសេស គឺធ្វើឱ្យតំបន់ជ្រោយចង្វារ អូស៊ីអាយស៊ី កាន់តែមានភាពទាក់ទាញ និងមានការអភិវឌ្ឍ កាន់តែខ្លាំងឡើង
- ស្នើសុំដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលខណ្ឌជ្រោយចង្វារសូមមេត្តាពង្រឹងច្បាប់ អនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាពឱ្យបានរឹងមាំដើម្បី ធានាដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋទាំងអស់សូមស្នើសុំ ដល់ថ្នាក់ដឹកនាំ អជ្ញាធរមានសមត្ថកិច្ចដែលសហការជាមួយស្ថាប័នឯកជន ឬស្ថាប័នពាក់ព័ន្ធធ្វើ យ៉ាងណាអនុវត្តនូវការសាងសង់ដែលប្រកបទៅដោយគុណភាព និងប្រសិទ្ធិភាព
- រាល់ច្បាប់នៃការសាងសង់ ឬវិនិយោគផ្សេងៗ ត្រូវគោរពតាមគោលការណ៍ស្តង់ដារនៃច្បាប់ដែល រាជរដ្ឋាភិបាលបានកំណត់ដើម្បី ឱ្យទទួលបាននូវគុណភាពពិតនៃការសាងសង់សម្រាប់បម្រើដល់ ការរស់នៅរបស់ប្រជាពលរដ្ឋ
- សូមស្នើសុំដល់និស្សិត និងអ្នកដែលបានអានលើប្រធានបទសារណារបស់នាងខ្ញុំ និងខ្ញុំបាទសូម មេត្តាចូលរួមចែករំលែកនូវចំណេះដឹងទៅតាមលទ្ធភាព ចូលរួមក្នុងការថែរក្សានូវសមិទ្ធផលថ្មីផ្សេងៗ បន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពី សំណង់, លេខនស/រកម/១១១៩/០១៩, ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩
- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ, លេខនស/រកម/១២៩៦/៣៦, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ, លេខ៥៧៧ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣
- អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ, លេខ០៣ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌកំបូលនៃរាជធានីភ្នំពេញ,លេខ០៤អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិច, លេខ១៦៨ អនក្រ.បក, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹង, លេខ៣៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន, លេខ៨០ ប្រក.មផ-បស្ថ, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣
- សេចក្តីណែនាំស្តីពី ចំណីអាហារនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន, លេខ១៨ អយក.សណន, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩
- ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព, លេខ០២០ ផ.ក, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## ២. ឯកសារយោងជាសៀវភៅ

- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣

## ៣. ឯកសារយោងជាគេហទំព័រ


- គេហទំព័រក្រសួងមហាផ្ទៃ https://www.interior.gov.kh/report/detail/2325
- គេហទំព័រ http://www.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html
- គេហទំព័រ https://www.propertyarea.asia/
- គេហទំព័រ https://www.khsearch.com/qna/16521
- គេហទំព័រ http://Www.ocic.kh.com
- គេហទំព័រ https://www.khsearch.com/qna/1292
- គេហទំព័រhttps://m.freshnewsasia.com/index.php/en/localnews/229877-2022-02-01-06-14-26.html
- គេហទំព័រ https://www.khsearch.com/qna/5637
- គេហទំព័រ https://www.khsearch.com/qna/11287
- គេហទំព័រ https://cambo-report.com/article/96
- គេហទំព័រ https://social.sabay.com.kh/article/1309114
- គេហទំព័រ news.sabay.com.kh ( https://news.sabay.com.kh/article/1300446 )
- គេហទំព័រ https://cambodiapropertyreport.com/article/4814
- គេហទំព័រ FRESH NEWS ( https://m.freshnewsasia.com/index.php/en/11318-2015-10-16-08-45-32.html )
- គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/
- គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ, លេខ៥៧៧ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ, លេខ០៣ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ, លេខ០៤ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២ អនក្រ .បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

**ឧបសម្ព័ន្ធទី៧៖** ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព, លេខ០២០ ផ.ក, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌជ្រោយចង្វារ

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗនៅក្នុងខណ្ឌជ្រោយចង្វារ និងសោភ័ណភាពរបស់ខណ្ឌជ្រោយចង្វារ

**ឧបសម្ព័ន្ធទី៣៖** ការិយាល័យរបស់ក្រុមហ៊ុនអូស៊ីអាយស៊ី

**ឧបសម្ព័ន្ធទី៤៖** សកម្មភាពរបស់ក្រុមហ៊ុនអូស៊ីអាយស៊ី

# ឧបសម្ព័ន្ធគតិយុត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត**ខណ្ឌជ្រោយចង្វារ** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន **០៥** ពីខណ្ឌឫស្សីកែវ នៃរាជធានីភ្នំពេញគឺ សង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់កោះដាច់ និងសង្កាត់បាក់ខែង។

ព្រំប្រទល់រដ្ឋបាល**ខណ្ឌជ្រោយចង្វារ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ទីតាំងសាលា**ខណ្ឌជ្រោយចង្វារ** ត្រូវស្ថិតនៅក្នុងសង្កាត់ព្រែកលៀប។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ខណ្ឌជ្រោយចង្វារ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌឫស្សីកែវ អភិបាលខណ្ឌឫស្សីកែវ និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៣.....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញគឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិច សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។

ព្រំប្រទល់រដ្ឋបាលខណ្ឌបឹងកេងកង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌចំការមនដែលស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ទៅឲ្យសាលាខណ្ឌបឹងកេងកង។

ទីតាំងសាលាខណ្ឌចំការមន ត្រូវស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌបឹងកេងកង គណៈអភិបាលខណ្ឌបឹងកេងកង និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...០៤...អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩.ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៦ ពីខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញគឺ សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់ឪឡោក សង្កាត់ស្នោរ សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ និងកាត់យកសង្កាត់ចំនួន០១ ពីខណ្ឌដង្កោ នៃរាជធានីភ្នំពេញគឺ សង្កាត់ប្រទះឡាង។

ព្រំប្រទល់រដ្ឋបាលខណ្ឌកំបូល ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ខណ្ឌកំបូល មានសង្កាត់ចំនួន០៧ គឺ សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់ឪឡោក សង្កាត់ស្នោរ សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ និងសង្កាត់ប្រទះឡាង។

ទីតាំងសាលាខណ្ឌកំបូល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌកំបូល ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ គណៈអភិបាលខណ្ឌពោធិ៍សែនជ័យ ក្រុមប្រឹក្សាខណ្ឌដង្កោ គណៈអភិបាលខណ្ឌដង្កោ ក្រុមប្រឹក្សាខណ្ឌកំបូល គណៈអភិបាលខណ្ឌកំបូល និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្រ្តី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹកអ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ទនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកល្អ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសំណល់

## និងសារធាតុប្រកបដោយគ្រោះថ្នាក់

### មាត្រា ៤.-

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

### មាត្រា ៥.-

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៦.-

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ៧.-

ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

កំរិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៨.-

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចោញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចោញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចោញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចោញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចោញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្ដេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ក្រសួងមហាផ្ទៃ

# ផែនការណែនាំស្តីពី

# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព"

**លក្ខណៈសម្បត្តិភូមិ ឃុំ មានសុវត្ថិភាពរួមមាន៖**

១. គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២. គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

**រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

*លេខ៖ ០២០ ផ.ក*

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។

នាឱកាសមិទ្ទិញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាងភូមិ, **ឃុំមានសុវត្ថិភាព** ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យក**ភូមិ, ឃុំមានសុវត្ថិភាព** ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។

ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### I-គោលបំណង និងសំណូមពរ ៖

១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំង

ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។

២-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយភូមិ, ឃុំមានសុវត្ថិភាព** ។

**II-<u>លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព</u>**

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

**III-<u>វិធានការ និងផែនការសកម្មភាព</u>**

**ក-<u>វិធានការ៖</u>**

១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា (<u>ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និង</u>

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

៤-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ ០៤ស.រ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០៨.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាព៖**

១-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំ លេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២-នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បទ្ទវហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា**ភូមិ, ឃុំមានសុវត្ថិភាព** ។

**៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវ៖**

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនិមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (<u>ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "**ចលនាប្រជាការពារ**" លេខ ០៣៨ផក ចុះថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ</u>) ។ ក្នុងវេទិការនេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។

៥-ក្រសួងមហាផ្ទៃសូមអំពាវនាវៈ

-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

៦-ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនិមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" (ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ធិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥) ។

## IV-ការចាត់តាំងអនុវត្តៈ

១-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព**នេះ ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។

២-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក**ភូមិ**ជាគោលដៅដើម្បីសហការអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព** ។

៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "**ភូមិ, ឃុំ មានសុវត្ថិភាព**" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និង លើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសំរេច ។

៥-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និង ចាត់តាំងអនុវត្តជាទូទៅ ។

៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃលក្ខណៈសម្បត្តិរបស់ភូមិ, **ឃុំ មានសុវត្ថិភាព** ។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គល ដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

៧-អគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយភូមិ, **ឃុំមានសុវត្ថិភាព**នេះ ក្រសួងមហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យ ក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌជ្រោយចង្វារ

ផែនទីរដ្ឋបាលរាជធានីភ្នំពេញ




ផែនទីរដ្ឋបាលខណ្ឌជ្រោយចង្វារ



# ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌជ្រោយចង្វារ និងសោភ័ណភាពខណ្ឌជ្រោយចង្វារ



សាលាខណ្ឌជ្រោយចង្វារ



មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិ



សារមន្ទីគយ



រង្វង់មូលព្រហ្មមុខបួន



សណ្ឋាគារសុខា



ស្ពានបាទៀ



វិមានឈ្នះ-ឈ្នះ



ពហុកីឡាដ្ឋានមរតកតេជោ



សោភ័ណភាពពេលយប់ក្នុងតំបន់ជ្រោយចង្វារ



សោភ័ណភាពពេលថ្ងៃក្នុងតំបន់ជ្រោយចង្វារ

## ឧបសម្ព័ន្ធទី៣៖ ការិយាល័យរបស់ក្រុមហ៊ុនអូស៊ីអាយស៊ី





ការិយាល័យក្រុមហ៊ុនអូស៊ីអាយស៊ី

## ឧបសម្ព័ន្ធទី៤៖ សកម្មភាពរបស់ក្រុមហ៊ុនអូស៊ីអាយស៊ី




ពិធីចុះហត្ថលេខារវាងក្រុមហ៊ុនអូស៊ីអាយស៊ី និងក្រុមហ៊ុនប៊ីកស៊ី




ពិធីចុះហត្ថលេខារវាងក្រុមហ៊ុនអូស៊ីអាយស៊ី និងស៊ីប៊ីអរអ៊ីខេមបូឌា